ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ



# ច្បាប់
# ស្តីពី
# ប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែល មានអត្ថប្រយោជន៍ និង គំនូរឧស្សាហកម្ម

**(Law on Patents, Utility Model Certificates and Industrial Designs)**

បោះពុម្ពផ្សាយដោយ
ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

ក្រោមជំនួយថវិការបស់
ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន

ឆ្នាំ ២០០៦

# ព្រះរាជក្រម

នស/រកម/០១០៣/០០៥

## យើង

## ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

## រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

## និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

## ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើត ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

- បានទទួលយល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរឧស្សាហកម្ម ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ២០០២ នាសម័យប្រជុំពេញអង្គលើកទី ៩ នីតិកាល ទី ២ ហើយដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០២ នាសម័យប្រជុំពេញអង្គលើក ទី ៨ នីតិកាលទី ១ ដែលមានសេចក្តីទាំងស្រុងដូចតទៅ :

# ច្បាប់

# ស្តីពី

# ប្រកាសនីយបត្រតក្កកម្ម

# វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍

# និងគំនូរឧស្សាហកម្ម

# ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

ច្បាប់នេះមានគោលដៅការពារតក្កកម្មដែលបានទទួលប្រកាសនីយបត្រតក្កកម្ម ម៉ូដែលមានអត្ថប្រយោជន៍ដែលបានទទួលវិញ្ញាបនបត្រ និងការពារគំនូរឧស្សាហកម្ម ដែលបានចុះបញ្ជីនៅក្នុងព្រះរាជាណាចក្រកម្ពុជា ស្របតាមច្បាប់នេះ និងសន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្ម ។

**មាត្រា ២.-**

ច្បាប់នេះមានគោលបំណង :

១-លើកទឹកចិត្តចំពោះការច្នៃប្រឌិតថ្មី និងចំពោះការស្រាវជ្រាវ និងការអភិវឌ្ឍន៍វិទ្យាសាស្ត្រនិងបច្ចេកវិជ្ជា

២-ជំរុញនិងលើកទឹកចិត្តការធ្វើពាណិជ្ជកម្ម ក្នុងនិងក្រៅប្រទេសនិងការវិនិយោគ

៣-លើកទឹកចិត្តចំពោះការផ្ទេរបច្ចេកវិជ្ជាមកក្នុងព្រះរាជាណាចក្រកម្ពុជា ដើម្បីជួយសម្រួលសកម្មភាពឧស្សាហកម្ម និងការអភិវឌ្ឍន៍សេដ្ឋកិច្ច

៤-ផ្តល់ការការពារចំពោះសិទ្ធិនៃកម្មសិទ្ធិឧស្សាហកម្ម និងប្រឆាំងចំពោះការរំលោភសិទ្ធិខាងលើ ក៏ដូចជាប្រឆាំងនឹងការធ្វើជំនួញមិនស្របច្បាប់ ។

# ជំពូកទី ២

# ប្រកាសនីយបត្រតក្កកម្ម

## ផ្នែកទី ១

## តក្កកម្មដែលអាចផ្ដល់ប្រកាសនីយបត្រតក្កកម្មបាន

### មាត្រា ៣.-

ប្រកាសនីយបត្រតក្កកម្ម ក្នុងន័យនៃច្បាប់នេះ គឺជាវិញ្ញាបនបត្រដែលបានផ្ដល់ដើម្បីការពារតក្កកម្ម ។

តក្កកម្មក្នុងន័យនៃច្បាប់នេះ គឺជាគំនិតរបស់តក្ករដែលអាចយកទៅអនុវត្តបាន នៅក្នុងដំណោះស្រាយបញ្ហាជាក់លាក់ណាមួយក្នុងវិស័យបច្ចេកវិជ្ជា ។

តក្កកម្មអាចជាការរកឃើញផលិតផល ឬដំណើរការផលិតកម្ម ឬអាចជាការរកឃើញអ្វីមួយ ដែលទាក់ទងទៅនឹងផលិតផល ឬដំណើរការផលិតកម្ម ។

### មាត្រា ៤.-

តក្កកម្មខាងក្រោមនេះ មិនត្រូវការពារដោយប្រកាសនីយ-បត្រតក្កកម្មនៃច្បាប់នេះទេ :

១-ការរកឃើញ ទ្រឹស្ដីវិទ្យាសាស្ត្រ និងវិធីសាស្ត្រគណិតវិទ្យា

២-គម្រោងការ ក្បួន ឬវិធីសាស្ត្រសម្រាប់ធ្វើជំនួញសម្រាប់ធ្វើសកម្មភាពហិរញ្ញវត្ថុខាងប្រាជ្ញាសុទ្ធសាធ ឬសម្រាប់លេងល្បែងកំសាន្ត

៣-វិធីសាស្ត្រសម្រាប់ព្យាបាលរាងកាយមនុស្សឬសត្វ ដោយការវះកាត់ ឬដោយការព្យាបាល ក៏ដូចជាវិធីសាស្ត្រវិនិច្ឆ័យរោគ ដែលបានអនុវត្តលើរាងកាយមនុស្ស ឬសត្វ ។ បទប្បញ្ញត្តិនេះមិនយកមកអនុវត្តចំពោះផលិតផលទាំងឡាយដែលយកមកប្រើប្រាស់ក្នុងវិធីសាស្ត្រខាងលើនេះទេ

៤-ផលិតផលឱសថដូចមានចែងក្នុងមាត្រា ១៣៦ នៃច្បាប់នេះ

៥-រុក្ខជាតិ ឬសត្វដែលមិនមែនជាមីក្រូសរីរាង្គ និងដំណើរការកកើតតាមលក្ខណៈជីវសាស្ត្រសំខាន់ៗ សម្រាប់ផលិតកម្មរុក្ខជាតិឬសត្វ

៦-ប្រភេទផ្សេងៗនៃពូជរុក្ខជាតិណាមួយ ។

**មាត្រា ៥.-**

តក្កកម្មដែលអាចទទួលប្រកាសនីយបត្រតក្កកម្មបាន លុះត្រាតែតក្កកម្មនោះ :

១-ថ្មី

២-មានជំហានរកឃើញថ្មី និង

៣-អាចយកទៅអនុវត្តបាននៅក្នុងវិស័យឧស្សាហកម្ម ។

**មាត្រា ៦.-**

តក្កកម្មដែលអាចចាត់ទុកថាថ្មីបាន លុះត្រាតែតក្កកម្មនោះពុំទាន់មានអ្នកណាបានរកឃើញពីមុន ។

ការរកឃើញពីមុន គឺតក្កកម្មដែលសាធារណជន នៅកន្លែងណាមួយនៅលើពិភពលោកបានដឹងមុនកាលបរិច្ឆេទសុំចុះបញ្ជីសំណុំលិខិតស្នើសុំ ឬកាលបរិច្ឆេទអាទិភាពនៃសំណុំលិខិតស្នើសុំនោះ តាមរយៈការផ្សព្វផ្សាយ ដោយប្រើរូបភាពជាក់ស្តែង ឬដោយផ្ទាល់មាត់ តាមរយៈការប្រើប្រាស់តក្កកម្មនោះ ឬតាមរយៈមធ្យោបាយផ្សព្វផ្សាយផ្សេងៗទៀត ។

ក្នុងន័យនៃវាក្យខណ្ឌទី ២ នៃមាត្រានេះ មិនត្រូវចាត់ទុកថាជាការដឹងដល់សាធារណជន ចំពោះករណីដូចខាងក្រោម :

**ក**-ការដឹងដល់សាធារណជននូវតក្កកម្ម ដែលបានកើតឡើងក្នុងអំឡុងពេលដប់ពីរ(១២)ខែ មុនកាលបរិច្ឆេទសុំចុះបញ្ជីសំណុំលិខិតស្នើសុំ ឬកាលបរិច្ឆេទអាទិភាពនៃសំណុំលិខិតស្នើសុំនោះ។

**ខ**-ការធ្វើឱ្យលេចឮខ្ចរខ្ចាយពត៌មានស្តីអំពីតក្កកម្ម តាមរយៈអ្នកដាក់ពាក្យសុំ តាមរយៈអ្នកស្នងរបស់បុព្វជន ឬតាមរយៈការរំលោភរបស់ភាគីទីបីទៅលើអ្នកដាក់ពាក្យសុំ ឬអ្នកស្នងរបស់បុព្វជនដែលបណ្តាលឱ្យលេចឮខ្ចរខ្ចាយពត៌មាននេះ ។

**មាត្រា ៧.-**

ដោយពិនិត្យទៅលើការរកឃើញពីមុន ផ្អែកតាមសំណុំលិខិតស្នើសុំដែលអះអាងអំពីតក្កកម្មនោះ និងដូចដែលបានចែងនៅក្នុងវាក្យខណ្ឌទី ២ នៃមាត្រា ៦ នៃច្បាប់នេះ តក្កកម្មត្រូវចាត់ទុកថាមានជំហានរកឃើញថ្មី ប្រសិនបើតក្កកម្មនោះមិនអាចឱ្យបុគ្គលណាដែលមានកម្រិតធម្មតាក្នុងជំនាញយល់ដឹងបាន ។

**មាត្រា ៨.-**

តក្កកម្មមួយត្រូវចាត់ទុកថាអាចអនុវត្តបាននៅក្នុងវិស័យឧស្សាហកម្ម ប្រសិនបើតក្កកម្មនោះអាចត្រូវផលិត ឬត្រូវប្រើប្រាស់នៅក្នុងប្រភេទណាមួយនៃឧស្សាហកម្មបាន ។

**មាត្រា ៩.-**

តក្កកម្មណាដែលការធ្វើអាជីវកម្មពាណិជ្ជកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា

- ផ្ទុយនឹងសណ្តាប់ធ្នាប់សាធារណៈ ឬសីលធម៌
- មិនការពារជីវិត ឬសុខភាពរបស់មនុស្ស សត្វ ឬរុក្ខជាតិ
- ធ្វើឱ្យខូចបរិស្ថានធ្ងន់ធ្ងរ ឬ
- ត្រូវបានច្បាប់ហាមឃាត់

មិនត្រូវផ្តល់ប្រកាសនីយបត្រតក្កកម្មឱ្យទេ ។

## ផ្នែកទី ២

## សិទ្ធិជាម្ចាស់នៃប្រកាសនីយបត្រតក្កកម្ម និងការដាក់ឈ្មោះតក្កករ

**មាត្រា ១០.-**

សិទ្ធិជាម្ចាស់នៃប្រកាសនីយបត្រតក្កកម្មគឺជាកម្មសិទ្ធិរបស់តក្កករ ។

**មាត្រា ១១.-**

ប្រសិនបើមានបុគ្គលពីរនាក់ ឬច្រើននាក់រួមគ្នាបង្កើតបានតក្កកម្មមួយ សិទ្ធិជាម្ចាស់នៃប្រកាសនីយបត្រតក្កកម្មនេះ ត្រូវតែជាកម្មសិទ្ធិរួមគ្នានៃបុគ្គលទាំងឡាយនោះ ។

**មាត្រា ១២.-**

ប្រសិនបើមានបុគ្គលពីរនាក់ឬច្រើននាក់ បានរកឃើញដោយឡែកៗពីគ្នានូវតក្កកម្មមួយដូចគ្នា បុគ្គលណាបានដាក់សំណុំលិខិតស្នើសុំដែលមានកាលបរិច្ឆេទសុំចុះបញ្ជីមុនគេបង្អស់ ឬមានកាលបរិច្ឆេទអាទិភាពមុនគេបង្អស់ ហើយបានប្រកាសសុពលភាពនៃកាលបរិច្ឆេទអាទិភាពនោះ ត្រូវទទួលសិទ្ធិជាម្ចាស់ប្រកាសនីយបត្រតក្កកម្ម ប្រសិនបើសំណុំលិខិតស្នើសុំខាងលើមិនត្រូវដកយកទៅវិញ ឬបោះបង់ចោល ឬក៏ត្រូវបដិសេធ ។

**មាត្រា ១៣.-**

សិទ្ធិជាម្ចាស់នៃប្រកាសនីយបត្រតក្កកម្ម អាចប្រគល់ឬផ្ទេរទៅឱ្យបុគ្គលដទៃដើម្បីស្នងជំនួសបាន ។

**មាត្រា ១៤.-**

តក្កកម្មមួយដែលធ្វើឡើងនៅក្នុងការប្រតិបត្តិទៅតាមកិច្ចសន្យាជួលធ្វើការងារ សិទ្ធិជាម្ចាស់នៃប្រកាសនីយបត្រតក្កកម្មត្រូវតែជាកម្មសិទ្ធិរបស់និយោជក ប្រសិនបើនៅក្នុងកិច្ចសន្យានោះ ពុំមានប្រការអ្វីចែងផ្ទុយអំពីនេះ ។

**មាត្រា ១៥.-**

តក្កករត្រូវតែដាក់ឈ្មោះរបស់ខ្លួននៅក្នុងប្រកាសនីយបត្រតក្កកម្ម លើកលែងតែតក្កករនោះបានចុះហត្ថលេខាលើសេចក្តីប្រកាសជាលាយលក្ខអក្សរពិសេសមួយផ្ញើជូនមន្ត្រីកាន់កាប់បញ្ជីដោយបញ្ជាក់ថាខ្លួនពុំមានបំណងឱ្យដាក់ឈ្មោះរបស់ខ្លួនឡើយ ទើបនៅលើប្រកាសនីយបត្រតក្កកម្មនោះមិនត្រូវដាក់ឈ្មោះតក្កករ ។ ការសន្យា ឬការទទួលរ៉ាប់រងណាមួយរបស់តក្កករដោយផ្ទាល់មាត់ធ្វើឡើងចំពោះបុគ្គលណាម្នាក់ដែលថាខ្លួននឹងធ្វើតាមសេចក្តីប្រកាសខាងលើ នឹងពុំមានប្រសិទ្ធភាពស្របច្បាប់ឡើយ ។

## ផ្នែកទី ៣
## សំណុំលិខិតស្នើសុំប្រកាសនីយបត្រតក្កកម្ម

**មាត្រា ១៦.-**

សំណុំលិខិតស្នើសុំប្រកាសនីយបត្រតក្កកម្មត្រូវដាក់ជូនទៅក្រសួងទទួលបន្ទុកឧស្សាហកម្មដែលក្នុងនោះត្រូវរួមមាន ពាក្យសុំ សេចក្តីអធិប្បាយអំពីតក្កកម្ម សេចក្តីអះអាង គំនូសបង្ហាញប្រសិនបើចាំបាច់និងខ្លឹមសារសង្ខេប ។ ការដាក់សំណុំលិខិតស្នើសុំត្រូវតែមានការបង់កម្រៃតាមការកំណត់ដូចមានចែងក្នុងមាត្រា ១៣០ នៃច្បាប់នេះ ។

**មាត្រា ១៧.-**

ពាក្យសុំត្រូវមានបញ្ជាក់អំពីអ្វីដែលអាចឈានទៅដល់ការ

ផ្តល់ប្រកាសនីយបត្រតក្កកម្មបាន ដូចជានាម និងទិន្នន័យផ្សេងៗ ដែលពាក់ព័ន្ធទៅនឹងអ្នកដាក់ពាក្យសុំ តក្កករ និងភ្នាក់ងារតំណាង ប្រសិនបើមាន និងចំណងជើងនៃតក្កកម្មនោះ ។

ក្នុងករណីអ្នកដាក់ពាក្យសុំមិនមែនជាតក្កករទេនោះ ពាក្យសុំត្រូវតែភ្ជាប់មកជាមួយនូវឯកសារបញ្ជាក់អំពីសិទ្ធិរបស់អ្នកដាក់ពាក្យសុំចំពោះប្រកាសនីយបត្រតក្កកម្មនោះ ។

**មាត្រា ១៨.-**

សេចក្តីអធិប្បាយត្រូវលើកបង្ហាញអំពីតក្កកម្មក្នុងលក្ខណៈច្បាស់លាស់និងពេញលេញ ដើម្បីឱ្យបុគ្គលដែលមានកម្រិតជំនាញធម្មតាក្នុងជំនាញអាចអនុវត្តបាននូវតក្កកម្មនោះ ។ ដោយឡែកសេចក្តីអធិប្បាយនោះ ត្រូវចង្អុលបង្ហាញឱ្យដឹងនូវវិធីដែលល្អជាងគេដើម្បីអនុវត្តតាមបាននូវតក្កកម្មខាងលើ នៅពេលចុះកាលបរិច្ឆេទសុំចុះបញ្ជី ឬនៅពេលចុះកាលបរិច្ឆេទអាទិភាពនៃសំណុំលិខិតស្នើសុំក្នុងករណីអាទិភាពត្រូវបានអះអាង ។

**មាត្រា ១៩.-**

សេចក្តីអះអាងត្រូវតែកំណត់ឱ្យបានច្បាស់លាស់ អំពីចំណុចដែលសុំឱ្យមានការការពារ ។ សេចក្តីអធិប្បាយនិងគំនូសបង្ហាញអាចត្រូវយកទៅប្រើប្រាស់បានសម្រាប់ធ្វើការបកស្រាយសេចក្តីអះអាងនោះ ។

សេចក្តីអះអាងត្រូវតែច្បាស់លាស់ និងសង្ខេប ។ សេចក្តី

អះអាងនោះត្រូវតែផ្អែកទាំងស្រុងលើសេចក្តីអធិប្បាយ ។

**មាត្រា ២០.-**

គំនូសបង្ហាញចាំបាច់ត្រូវតែមាន ដើម្បីយកមកបកស្រាយពន្យល់អំពីតក្កកម្មនោះ ។

**មាត្រា ២១.-**

ខ្លឹមសារសង្ខេបត្រូវបកស្រាយត្រឹមតែគោលបំណងនៃពត៌មានបច្ចេកទេសប៉ុណ្ណោះ មិនត្រូវបកស្រាយអំពីវិសាលភាពនៃការការពារឡើយ ។

**មាត្រា ២២.-**

អ្នកដាក់ពាក្យសុំអាចដកសំណុំលិខិតស្នើសុំទៅវិញនៅពេលណាក៏បាន ក្នុងករណីដែលសំណុំលិខិតស្នើសុំនោះស្ថិតក្នុងរយៈពេលព្យួរទុកសម្រាប់ពិនិត្យ ដើម្បីផ្តល់ប្រកាសនីយបត្រតក្កកម្ម ។

## ផ្នែកទី ៤
## ការរួមបញ្ចូលតែមួយនៃតក្កកម្ម
## ការកែតម្រូវនិងការបំបែកសំណុំលិខិតស្នើសុំ

**មាត្រា ២៣.-**

សំណុំលិខិតស្នើសុំត្រូវពាក់ព័ន្ធទៅនឹងតក្កកម្មតែមួយគត់ ឬតក្កកម្មមួយក្រុមដែលទាក់ទងគ្នាបង្កើតបានជាទស្សនៈរួមមួយនៃតក្កកម្មនោះ ។

**មាត្រា ២៤.-**

មុនពេលផ្តល់ប្រកាសនីយបត្រតក្កកម្ម អ្នកដាក់ពាក្យសុំអាចកែតម្រូវសំណុំលិខិតស្នើសុំរបស់ខ្លួនបាន ប៉ុន្តែការកែតម្រូវនោះមិនត្រូវបន្ថែមអ្វីឱ្យ លើសពីខ្លឹមសារដែលបានបញ្ជាក់នៅក្នុងសំណុំលិខិតស្នើសុំពីដំបូងឡើយ ។

**មាត្រា ២៥.-**

មុនពេលផ្តល់ប្រកាសនីយបត្រតក្កកម្ម អ្នកដាក់ពាក្យសុំអាចសុំបំបែកសំណុំលិខិតស្នើសុំជាពីរ ឬច្រើនបានដែលហៅថាសំណុំលិខិតស្នើសុំបំបែក ។ ប៉ុន្តែសំណុំលិខិតស្នើសុំបំបែកនោះ មិនត្រូវបន្ថែមអ្វីឱ្យលើសពីខ្លឹមសារដែលបានបញ្ជាក់នៅក្នុងសំណុំលិខិតស្នើសុំពីដំបូងឡើយ ។

សំណុំលិខិតស្នើសុំបំបែកនីមួយៗ ត្រូវទទួលបានកាលបរិច្ឆេទសុំចុះបញ្ជី និងកាលបរិច្ឆេទអាទិភាព ដូចសំណុំលិខិតស្នើសុំពីដំបូងដែរ ។

**មាត្រា ២៦.-**

ក្នុងករណីដែលប្រកាសនីយបត្រតក្កកម្មមួយ ត្រូវផ្តល់រួចហើយទៅតាមសំណុំលិខិតស្នើសុំដែលមិនបានបំពេញតាមល័ក្ខខ័ណ្ឌតម្រូវនៃការរួមបញ្ចូលតែមួយនៃតក្កកម្មដូចបានចែងនៅក្នុងមាត្រា ២៣ នៃច្បាប់នេះ មិនត្រូវចាត់ទុកជាមូលហេតុនៃអសុពលភាពរបស់

ប្រកាសនីយបត្រតក្កកម្មនោះបានឡើយ ។

## ផ្នែកទី ៥
## សិទ្ធិអាទិភាព

**មាត្រា ២៧.-**

យោងតាមអនុសញ្ញាទីក្រុងប៉ារីស សំណុំលិខិតស្នើសុំប្រកាសនីយបត្រតក្កកម្ម អាចអមដោយសេចក្តីប្រកាសមួយដែលអះអាងអំពីអាទិភាពនៃសំណុំលិខិតស្នើសុំដែលបានសុំចុះបញ្ជីមុនគេដោយអ្នកដាក់ពាក្យសុំ ឬដោយអ្នកស្នងជំនួសឱ្យបុព្វជនរបស់គេនៅក្នុងប្រទេសមួយ ឬច្រើននៅក្នុងតំបន់ ឬនៅអន្តរជាតិ ដែលប្រទេសទាំងនោះជាសមាជិកអនុសញ្ញាខាងលើ ឬដែលជាសមាជិកនៃអង្គការពាណិជ្ជកម្មពិភពលោក ។

**មាត្រា ២៨.-**

ក្នុងករណីដែលសំណុំលិខិតស្នើសុំប្រកាសនីយបត្រតក្កកម្មមានអមដោយសេចក្តីប្រកាស ដូចមានចែងនៅក្នុងមាត្រា ២៧ នៃច្បាប់នេះ អ្នកដាក់ពាក្យសុំត្រូវផ្តល់ដល់មន្ត្រីកាន់កាប់បញ្ជីតាមពេលវេលាកំណត់នូវឯកសារចម្លងនៃសំណុំលិខិតស្នើសុំដែលបានដាក់មុនគេ និងត្រូវមានការបញ្ជាក់ថាត្រឹមត្រូវតាមច្បាប់ដើមដោយការិយាល័យដែលបានទទួលសំណុំលិខិតស្នើសុំនោះ ។

**មាត្រា ២៩.-**

អានុភាពនៃសេចក្តីប្រកាសខាងលើ ដូចមានចែងនៅក្នុងមាត្រា ២៧ នៃច្បាប់នេះ ត្រូវបានកំណត់នៅក្នុងអនុសញ្ញាទីក្រុងប៉ារីស ។

ប្រសិនបើមន្ត្រីកាន់កាប់បញ្ជីពិនិត្យឃើញថា លក្ខខណ្ឌតម្រូវនៅក្រោមផ្នែកទី ៥ នៃជំពូកទី ២ នៃច្បាប់នេះ និងបទបញ្ជាទាំងឡាយដែលពាក់ព័ន្ធនឹងផ្នែកនេះមិនបានបំពេញត្រឹមត្រូវទេនោះសេចក្តីប្រកាសអមខាងលើត្រូវចាត់ទុកថាមិនបានធ្វើឡើយ ។

## ផ្នែកទី ៦

## ពត៌មានស្តីអំពីសំណុំលិខិតស្នើសុំនៅឯបរទេស និងប្រកាសនីយបត្រតក្កកម្មបរទេស

**មាត្រា ៣០.-**

នៅពេលមានសំណើពីមន្ត្រីកាន់កាប់បញ្ជី អ្នកដាក់ពាក្យសុំត្រូវតែផ្តល់ជូនមន្ត្រីកាន់កាប់បញ្ជីនូវកាលបរិច្ឆេទនិងលេខនៃសំណុំលិខិតស្នើសុំទាំងឡាយដែលខ្លួនបានដាក់នៅឯបរទេស ដែលមានការពាក់ព័ន្ធទៅនឹងតក្កកម្មដូចគ្នា ឬស្ទើរតែដូចគ្នាដូចបានអះអាងនៅក្នុងសំណុំលិខិតស្នើសុំដែលបានដាក់នៅក្រសួងទទួលបន្ទុកឧស្សាហកម្ម។

**មាត្រា ៣១.-**

យោងតាមមាត្រា ៣០ នៃច្បាប់នេះ នៅពេលមានសំណើពីមន្ត្រីកាន់កាប់បញ្ជី អ្នកដាក់ពាក្យសុំត្រូវតែផ្តល់ជូនមន្ត្រីកាន់កាប់បញ្ជី នូវ

ឯកសារដែលពាក់ព័ន្ធទៅនឹងសំណុំលិខិតស្នើសុំនៅឯបរទេស ដែលបានដាក់នៅប្រទេសណាមួយ ឬច្រើនដូចខាងក្រោម :

**ក**-ឯកសារចម្លងនៃលិខិតឆ្លងឆ្លើយ ដែលពាក់ព័ន្ធទៅនឹងលទ្ធផលនៃការស្រាវជ្រាវ ឬលទ្ធផលនៃការពិនិត្យសំណុំលិខិតស្នើសុំនៅឯបរទេស ដែលអ្នកដាក់ពាក្យសុំបានទទួល ។

**ខ**-ឯកសារចម្លងនៃប្រកាសនីយបត្រតក្កកម្ម ដែលបរទេសបានផ្ដល់ជូនតាមការដាក់សំណុំលិខិតស្នើសុំនៅឯបរទេស ។

**គ**-ឯកសារចម្លងនៃសេចក្ដីសម្រេចចុងក្រោយដែលបដិសេធ មិនទទួលសំណុំលិខិតស្នើសុំនៅឯបរទេស ឬបដិសេធមិនផ្ដល់ជូននូវប្រកាសនីយបត្រតក្កកម្ម តាមសំណើនៃសំណុំលិខិតស្នើសុំនោះ ។

យោងតាមវាក្យខណ្ឌទី ១ នៃមាត្រានេះ នៅពេលមានសំណើពីមន្ត្រីកាន់កាប់បញ្ជី អ្នកដាក់ពាក្យសុំត្រូវផ្ដល់នូវឯកសារចម្លងនៃសេចក្ដីសម្រេចចុងក្រោយស្ដីអំពីអសុពលភាពនៃប្រកាសនីយបត្រតក្កកម្មដែលបានផ្ដល់ជូន ផ្អែកតាមការដាក់សំណុំលិខិតស្នើសុំនៅឯបរទេស ។

**មាត្រា ៣២.-**

ក្នុងករណីនាយកដ្ឋានទទួលបន្ទុកចុះបញ្ជីដែលបានបង្កើតឡើងតាមមាត្រា ១១៧ នៃច្បាប់នេះ អនុវត្តតួនាទីជាការិយាល័យជ្រើសតាំង ដូចមានចែងក្នុងមាត្រា ៨៣ នៃច្បាប់នេះ ចំណុច **ក** និងចំណុច **គ** របស់វាក្យខណ្ឌទី ១ នៃមាត្រា ៣១ នៃច្បាប់នេះ

មិនត្រូវយកមកអនុវត្តទេ អំពីពត៌មានទាក់ទងទៅនឹងការពិនិត្យរបស់ការិយាល័យជ្រើសតាំងផ្សេងៗទៀត លើសំណុំលិខិតស្នើសុំអន្តរជាតិដដែលនោះ ។

## ផ្នែកទី ៧
## កាលបរិច្ឆេទនៃការសុំចុះបញ្ជី និងការពិនិត្យ

**មាត្រា ៣៣.–**

មន្ត្រីកាន់កាប់បញ្ជី ត្រូវទទួលស្គាល់កាលបរិច្ឆេទនៃការទទួលសំណុំលិខិតស្នើសុំថាជាកាលបរិច្ឆេទនៃការសុំចុះបញ្ជីសំណុំលិខិតស្នើសុំបាន លុះត្រាតែនៅពេលដែលទទួលនោះ សំណុំលិខិតមានអមដោយ ឯកសារត្រឹមត្រូវដូចខាងក្រោម :

១-ការបញ្ជាក់យ៉ាងច្បាស់លាស់ ឬគ្រប់គ្រាន់ អំពីបំណងនៃការសុំផ្តល់ប្រកាសនីយបត្រតក្កកម្ម

២-ការបញ្ជាក់អំពីអត្តសញ្ញាណនៃអ្នកស្នើសុំ

៣-ផ្នែកមួយនៃសំណុំលិខិតស្នើសុំ ដែលនៅលើផ្នែកនោះមានបញ្ជាក់នូវសេចក្តីអធិប្បាយរបស់តក្កកម្ម ។

នៅពេលបានទទួលសំណុំលិខិតស្នើសុំ ប្រសិនបើមន្ត្រីកាន់កាប់បញ្ជីពិនិត្យឃើញថាសំណុំលិខិតស្នើសុំនោះមិនបានបំពេញត្រឹមត្រូវទៅតាមល័ក្ខខ័ណ្ឌតម្រូវរបស់វាក្យខណ្ឌទី ១ នៃមាត្រានេះទេ មន្ត្រីកាន់កាប់បញ្ជីត្រូវស្នើឱ្យអ្នកដាក់ពាក្យសុំធ្វើការកែតម្រូវទៅតាមល័ក្ខខ័ណ្ឌតម្រូវនោះ និងកត់ត្រាកាលបរិច្ឆេទសុំចុះបញ្ជីសំណុំលិខិតស្នើសុំទៅតាមកាលបរិច្ឆេទដែលបានទទួលការកែតម្រូវ ។ ប៉ុន្តែប្រសិនបើសំណុំ

លិខិតស្នើសុំមិនបានកែតម្រូវទៅតាមការណែនាំទេ សំណុំលិខិតស្នើសុំនោះ ត្រូវបានចាត់ទុកថាដូចជាមិនបានសុំចុះបញ្ជីឡើយ ។

**មាត្រា ៣៤.-**

ក្នុងករណីដែលសំណុំលិខិតស្នើសុំបានយោងទៅគំនូសបង្ហាញ ហើយអ្នកដាក់ពាក្យសុំមិនបានភ្ជាប់មកជាមួយទេ មន្ត្រីកាន់កាប់បញ្ជីត្រូវឱ្យអ្នកដាក់ពាក្យសុំផ្តល់នូវគំនូសបង្ហាញដែលមិនបានភ្ជាប់មកជាមួយនោះ ។ ប្រសិនបើអ្នកដាក់ពាក្យសុំបានអនុវត្តតាមការណែនាំរួចហើយ មន្ត្រីកាន់កាប់បញ្ជីត្រូវកត់ត្រាកាលបរិច្ឆេទនៃការសុំចុះបញ្ជីសំណុំលិខិតស្នើសុំ ទៅតាមកាលបរិច្ឆេទទទួលគំនូសបង្ហាញដែលពីមុនមកអ្នកដាក់ពាក្យសុំមិនបានភ្ជាប់ជាមួយ ។ បើមិនដូច្នោះទេ មន្ត្រីកាន់កាប់បញ្ជីត្រូវកត់ត្រាកាលបរិច្ឆេទនៃការសុំចុះបញ្ជីសំណុំលិខិតស្នើសុំទៅតាមកាលបរិច្ឆេទទទួលសំណុំលិខិតស្នើសុំ ហើយត្រូវចាត់ទុកសំណុំលិខិតស្នើសុំនោះថាពុំមានគំនូសបង្ហាញឡើយ ។

**មាត្រា ៣៥.-**

បន្ទាប់ពីបានយល់ព្រមលើកាលបរិច្ឆេទសុំចុះបញ្ជី មន្ត្រីកាន់កាប់បញ្ជីត្រូវពិនិត្យមើលសំណុំលិខិតស្នើសុំនោះឱ្យបំពេញត្រឹមត្រូវទៅតាមល័ក្ខខ័ណ្ឌតម្រូវ ដែលបានចែងនៅក្នុងមាត្រា ១៦ និងមាត្រា ១៧ នៃច្បាប់នេះ និងល័ក្ខខ័ណ្ឌតម្រូវនានាដែលបានកំណត់ជាបទបញ្ញាចាំបាច់នៃច្បាប់នេះ ។ ក្នុងករណីដែលសំណុំលិខិតស្នើសុំនិងប្រកាសនីយបត្រតក្កកម្មមានទំនាក់ទំនងនឹងបរទេសមន្ត្រីកាន់កាប់

បញ្ជីត្រូវពិនិត្យមើលឱ្យគ្រប់គ្រាន់បន្ថែមទៀត អំពីពត៌មាននៃលក្ខខ័ណ្ឌតម្រូវ ដែលមានចែងនៅក្នុងមាត្រា ៣០ មាត្រា ៣១ និងមាត្រា ៣២ នៃច្បាប់នេះ ។

**មាត្រា ៣៦.-**

ក្នុងករណីមន្ត្រីកាន់កាប់បញ្ជីពិនិត្យឃើញថា សំណុំលិខិតស្នើសុំបានបំពេញតាមលក្ខខ័ណ្ឌតម្រូវដូចបានកំណត់ក្នុងមាត្រា ៣៥ នៃច្បាប់នេះរួចហើយ មន្ត្រីកាន់កាប់បញ្ជីត្រូវពិនិត្យបន្តទៀតនូវលក្ខខ័ណ្ឌតម្រូវដែលបានកំណត់នៅក្នុងវាក្យខណ្ឌ ទី ២ និងទី ៣ នៃមាត្រា ៣ លក្ខខ័ណ្ឌតម្រូវនៅក្នុងមាត្រា ៤ ដល់មាត្រា ៩ មាត្រា ១៨ ដល់មាត្រា ២០ មាត្រា ២៣ ដល់មាត្រា ២៦ នៃច្បាប់នេះ និងបទបញ្ញាទាំងឡាយដែលពាក់ព័ន្ធនឹងច្បាប់នេះ ។

**មាត្រា ៣៧.-**

យោងតាមមាត្រា ៣៦ នៃច្បាប់នេះ មន្ត្រីកាន់កាប់បញ្ជីត្រូវពិនិត្យបន្ថែមនូវចំណុចដូចខាងក្រោមនេះ :

១-លទ្ធផលនៃរបាយការណ៍ស្រាវជ្រាវរបស់អន្តរជាតិ និងលទ្ធផលរបាយការណ៍ពិនិត្យជំហានដំបូងរបស់អន្តរជាតិ ដែលធ្វើឡើងតាមសន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្មរបស់សំណុំលិខិតស្នើសុំ

២-របាយការណ៍ស្រាវជ្រាវ និងរបាយការណ៍ពិនិត្យ ដែលបានចែងនៅក្នុងចំណុច **ក** របស់វាក្យខណ្ឌទី ១ នៃមាត្រា ៣១ ឬសេចក្តីសម្រេចចុងក្រោយដែលបានចែងនៅក្នុងចំណុច **គ** របស់

វាក្យខណ្ឌទី ១ នៃមាត្រា ៣១ នៃច្បាប់នេះស្តីអំពីការបដិសេធផ្តល់ប្រកាសនីយបត្រតក្កកម្ម ចំពោះសំណុំលិខិតស្នើសុំនៅឯបរទេស

៣-របាយការណ៍ស្រាវជ្រាវ និងរបាយការណ៍ពិនិត្យដែលបានធ្វើឡើងដោយស្ថាប័នស្រាវជ្រាវនិងពិនិត្យនៅក្រៅប្រទេស តាមសំណើរបស់មន្ត្រីកាន់កាប់បញ្ជី ។

## ផ្នែកទី ៨
## ការផ្តល់ប្រកាសនីយបត្រតក្កកម្ម
## និងការផ្លាស់ប្តូរនៅក្នុងប្រកាសនីយបត្រតក្កកម្ម

**មាត្រា ៣៨.-**

ក្នុងករណីដែលមន្ត្រីកាន់កាប់បញ្ជីពិនិត្យឃើញថាល័ក្ខខ័ណ្ឌដែលមានចែងនៅក្នុងមាត្រា ៣៥ និងមាត្រា ៣៦ នៃច្បាប់នេះត្រូវបំពេញរួចហើយនោះ មន្ត្រីកាន់កាប់បញ្ជីត្រូវដំណើរការផ្តល់ប្រកាសនីយបត្រតក្កកម្មជូនអ្នកដាក់ពាក្យសុំ ។ បើមិនដូច្នោះទេ មន្ត្រីកាន់កាប់បញ្ជីត្រូវបដិសេធសំណុំលិខិតស្នើសុំនិងជូនដំណឹងទៅអ្នកដាក់ពាក្យសុំអំពីសេចក្តីសម្រេចនេះ ។

**មាត្រា ៣៩.-**

នៅពេលផ្តល់ប្រកាសនីយបត្រតក្កកម្ម មន្ត្រីកាន់កាប់បញ្ជីត្រូវៈ

១-ចុះផ្សាយសេចក្តីបញ្ជាក់អំពីការផ្តល់ប្រកាសនីយបត្រ-តក្កកម្ម

២-ចេញលិខិតបញ្ជាក់អំពីការផ្តល់ប្រកាសនីយបត្រ-

តក្កកម្មមួយច្បាប់ និងប្រកាសនីយបត្រតក្កកម្មចម្លងមួយច្បាប់ ជូនដល់អ្នកដាក់ពាក្យសុំ

៣-កត់ត្រាប្រកាសនីយបត្រតក្កកម្មនៅក្នុងបញ្ជី

៤-ច្បាប់ចម្លងនៃប្រកាសនីយបត្រតក្កកម្មត្រូវមានសម្រាប់សាធារណជនជាវតាមតម្លៃដែលបានកំណត់ ។

**មាត្រា ៤០.-**

នៅពេលមានសំណើពីម្ចាស់ប្រកាសនីយបត្រតក្កកម្ម ផ្អែកលើមូលដ្ឋាននៃប្រកាសនីយបត្រតក្កកម្មដែលបានផ្តល់ជូនរួចហើយ មន្ត្រីកាន់កាប់បញ្ជីអាចធ្វើការកែសម្រួលបាននៅក្នុងអត្ថបទឬគំនូសបង្ហាញរបស់ប្រកាសនីយបត្រតក្កកម្មនោះ ដើម្បីកំណត់ទំហំនៃការការពារដែលផ្តល់ដោយប្រកាសនីយបត្រតក្កកម្ម ឱ្យតែការកែសម្រួលនោះមិនមានឥទ្ធិពលនាំឱ្យប្រែប្រួលលើសពីខ្លឹមសារ ដូចបានចែងនៅក្នុងសំណុំលិខិតស្នើសុំពីដំបូងដែលសម្រាប់ធ្វើជាមូលដ្ឋានឈានទៅដល់ការផ្តល់ប្រកាសនីយបត្រតក្កកម្មនោះ ។

## ផ្នែកទី ៩

## សិទ្ធិដែលបានប្រគល់តាមរយៈប្រកាសនីយបត្រតក្កកម្ម

**មាត្រា ៤១.-**

ការធ្វើអាជីវកម្ម នៅក្នុងព្រះរាជាណាចក្រកម្ពុជានូវតក្កកម្មដែលបានទទួលប្រកាសនីយបត្រតក្កកម្មរួចហើយដោយបុគ្គលដទៃទៀត ចាំបាច់ត្រូវតែមានការយល់ព្រមពីម្ចាស់ប្រកាសនីយបត្រតក្កកម្ម

នោះ ។

**មាត្រា ៤២.-**

ក្នុងន័យនៃច្បាប់នេះ ការធ្វើអាជីវកម្មនៃតក្កកម្មដែលបានទទួលប្រកាសនីយបត្រតក្កកម្មរួចហើយ គឺមានន័យថា ជាសកម្មភាពណាមួយនៃសកម្មភាពទាំងឡាយខាងក្រោមនេះ :

១-ចំពោះផលិតផលមួយ ដែលបានផ្ដល់ជូននូវប្រកាស-នីយបត្រតក្កកម្មរួចហើយ ការធ្វើអាជីវកម្មគឺជា :

**ក**-ការផលិត ការនាំចូល ការផ្គត់ផ្គង់សម្រាប់ការលក់និងការប្រើប្រាស់ផលិតផលនោះ

**ខ**-ការស្តុកទុកផលិតផលនោះ ក្នុងគោលបំណងផ្គត់ផ្គង់ សម្រាប់លក់ ឬប្រើប្រាស់

២-ចំពោះដំណើរការផលិតកម្មមួយ ដែលបានផ្ដល់ជូននូវប្រកាសនីយបត្រតក្កកម្មរួចហើយ ការធ្វើអាជីវកម្មគឺជា :

**ក**-ការប្រើប្រាស់ដំណើរការផលិតកម្មនោះ

**ខ**-ការធ្វើសកម្មភាពណាមួយនៃសកម្មភាពទាំងឡាយដូចមានចែងក្នុងចំណុច **ក** និងចំណុច **ខ** នៃចំណុចទី ១ នៃមាត្រានេះលើផលិតផលដែលទទួលបានដោយផ្ទាល់ពីមធ្យោបាយនៃដំណើរការផលិតកម្មនោះ ។

**មាត្រា ៤៣.-**

លើកលែងតែមាត្រា ៤៤ និងមាត្រា ៤៧ ដល់មាត្រា ៥៥ នៃច្បាប់នេះ ម្ចាស់ប្រកាសនីយបត្រតក្កកម្មមានសិទ្ធិប្ដឹងទៅតុលាការ

មានសមត្ថកិច្ច ចំពោះបុគ្គលណាដែលរំលោភលើប្រកាសនីយបត្រតក្កកម្មរបស់ខ្លួន តាមរយៈការអនុវត្តន៍ សកម្មភាពណាមួយដូចមានចែងក្នុងមាត្រា ៤២ នៃច្បាប់នេះ ដោយគ្មានការយល់ព្រមពីម្ចាស់ ឬមានសិទ្ធិប្តឹងចំពោះបុគ្គលណាដែលអនុវត្តសកម្មភាពទាំងឡាយដែលអាចនឹងបណ្តាលឱ្យមានការរំលោភដូចគ្នានេះកើតឡើង ។

**មាត្រា ៤៤.-**

សិទ្ធិដែលបានប្រគល់តាមរយៈប្រកាសនីយបត្រតក្កកម្មមិនអនុវត្តចំពោះ :

**ក**-សកម្មភាពពាក់ព័ន្ធនឹងសម្ភារៈ ដែលបានដាក់តាំងនៅលើទីផ្សារនៃព្រះរាជាណាចក្រកម្ពុជា ឬនៅលើទីផ្សារក្រៅព្រះរាជាណាចក្រកម្ពុជាដោយម្ចាស់ប្រកាសនីយបត្រតក្កកម្ម ឬដោយមានការយល់ព្រមពីម្ចាស់ប្រកាសនីយបត្រតក្កកម្ម

**ខ**-ការប្រើប្រាស់សម្ភារៈនៅលើអាកាសយាន យានយន្តផ្លូវគោក ឬនាវារបស់ប្រទេសដទៃ ដែលចូលចតជាបណ្តោះអាសន្ន ឬចូលចតដោយឧបទ្ទវហេតុក្នុងដែនអាកាស ដែនគោក ឬដែនទឹកនៃព្រះរាជាណាចក្រកម្ពុជា

**គ**-សកម្មភាពដែលធ្វើត្រឹមតែក្នុងគោលបំណងពិសោធន៍ដែលទាក់ទងទៅនឹងតក្កកម្មដែលបានផ្តល់ប្រកាសនីយបត្រតក្កកម្មរួចហើយ

**ឃ**-សកម្មភាពដែលប្រព្រឹត្តក្នុងគោលបំណងល្អ ដោយបុគ្គលណាម្នាក់ដោយប្រើប្រាស់តក្កកម្ម ឬក៏ធ្វើការរៀបចំឱ្យមាន

ប្រសិទ្ធភាពនិងហ្មត់ចត់នូវតក្កកម្មនោះ មុនកាលបរិច្ឆេទសុំចុះបញ្ជីសំណុំលិខិតស្នើសុំ ឬមុនកាលបរិច្ឆេទអាទិភាពនៃសំណុំលិខិតស្នើសុំដែលបានអះអាងក្នុងករណីដែលប្រកាសនីយបត្រតក្កកម្មបានផ្តល់រួចហើយ និងបានផ្តល់នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

យោងតាមចំណុច **ឃ** របស់វាក្យខណ្ឌទី ១ នៃមាត្រានេះ សិទ្ធិរបស់អ្នកប្រើប្រាស់មុន អាចផ្ទេរបានជាមួយតែសហគ្រាស ឬក្រុមហ៊ុន ឬមួយផ្នែកនៃសហគ្រាស ឬក្រុមហ៊ុនដែលបានប្រើប្រាស់ ឬបានរៀបចំការប្រើប្រាស់តក្កកម្មនោះរួចហើយ ។

## ផ្នែកទី ១០
## រយៈពេលនៃការការពារ និងការបង់កម្រៃប្រចាំឆ្នាំ

**មាត្រា ៤៥.-**

ប្រកាសនីយបត្រតក្កកម្ម មានសុពលភាពរយៈពេលម្ភៃ (២០)ឆ្នាំ គិតចាប់ពីកាលបរិច្ឆេទសុំចុះបញ្ជី នៃការស្នើសុំប្រកាសនីយបត្រតក្កកម្ម លុះត្រាតែបានបំពេញតាមល័ក្ខខ័ណ្ឌដូចមានចែងក្នុងមាត្រា ៤៦ នៃច្បាប់នេះ ។

**មាត្រា ៤៦.-**

ការបង់កម្រៃប្រចាំឆ្នាំ ត្រូវបង់ជាមុនជូនមន្ត្រីកាន់កាប់បញ្ជីសម្រាប់រយៈពេលមួយ(១)ឆ្នាំម្តងៗ ដោយគិតចាប់ពីពេលមួយ(១)ឆ្នាំក្រោយកាលបរិច្ឆេទសុំចុះបញ្ជីសំណុំលិខិតស្នើសុំប្រកាសនីយបត្រតក្ក-កម្ម ដើម្បីរក្សាសុពលភាពនៃប្រកាសនីយបត្រតក្កកម្ម ឬសំណុំលិខិត

ស្នើសុំនៃប្រកាសនីយបត្រតក្កកម្មនោះ ។ ការយឺតយ៉ាវក្នុងការបង់កម្រៃប្រចាំឆ្នាំ ត្រូវបានអនុញ្ញាតយ៉ាងយូរប្រាំមួយ(៦)ខែ ដោយមានការបង់កម្រៃបន្ថែមលើការយឺតយ៉ាវនេះ តាមការកំណត់ដូចមានចែងក្នុងមាត្រា ១៣០ នៃច្បាប់នេះ ។ ប្រសិនបើមិនបានបង់កម្រៃប្រចាំឆ្នាំ ទៅតាមល័ក្ខខ័ណ្ឌដែលមានចែងនៅក្នុងមាត្រានេះ សំណុំលិខិតស្នើសុំប្រកាសនីយបត្រតក្កកម្ម នឹងត្រូវចាត់ទុកថាបានដកយកទៅវិញ ឬប្រកាសនីយបត្រតក្កកម្មត្រូវអស់សុពលភាព ។

## ផ្នែកទី ១១
## ការធ្វើអាជីវកម្មដោយរដ្ឋាភិបាល ឬដោយបុគ្គលដែលបានទទួលការអនុញ្ញាតពីរដ្ឋាភិបាល

**មាត្រា ៤៧.-**

រដ្ឋមន្ត្រីអាចសម្រេចជ្រើសរើសឱ្យអង្គភាពរដ្ឋ ឬតតិយជនធ្វើអាជីវកម្មលើតក្កកម្មបាន ទោះជាគ្មានការយល់ព្រមពីម្ចាស់ប្រកាសនីយបត្រតក្កកម្មក៏ដោយ ចំពោះករណីដូចខាងក្រោម :

១-មានសេចក្ដីតម្រូវចាំបាច់ ដើម្បីបម្រើផលប្រយោជន៍សាធារណៈ ជាពិសេសផ្នែកសន្តិសុខជាតិ អាហារូបត្ថម្ភ សុខាភិបាល ឬដើម្បីអភិវឌ្ឍវិស័យសេដ្ឋកិច្ចជាតិសំខាន់ៗផ្សេងទៀត ឬ

២-តុលាការមានសមត្ថកិច្ចបានវិនិច្ឆ័យថា របៀបធ្វើអាជីវកម្មដោយម្ចាស់ប្រកាសនីយបត្រតក្កកម្ម ឬដោយអ្នកទទួលអាជ្ញាប័ណ្ណមានលក្ខណៈប្រឆាំងនឹងការប្រកួតប្រជែង ។

ការធ្វើអាជីវកម្មលើតក្កកម្មនោះ ត្រូវអនុវត្តតាមវត្ថុបំណងដែល

បានអនុញ្ញាត និងត្រូវបង់ប្រាក់សំណងសមស្របជូនម្ចាស់ប្រកាសនីយបត្រតក្កកម្ម ដោយគិតដល់តម្លៃសេដ្ឋកិច្ច ដូចបានកំណត់នៅក្នុងសេចក្តីអនុញ្ញាតរបស់រដ្ឋមន្ត្រី ។

រដ្ឋមន្ត្រីត្រូវធ្វើការសម្រេច បន្ទាប់ពីបានស្តាប់យោបល់របស់ម្ចាស់ប្រកាសនីយបត្រតក្កកម្ម និងបុគ្គលទាំងឡាយដែលពាក់ព័ន្ធក្នុងរឿងនេះ ។

**មាត្រា ៤៨.-**

ផ្អែកតាមសំណើរបស់ម្ចាស់ប្រកាសនីយបត្រតក្កកម្ម របស់អង្គភាពរដ្ឋ ឬរបស់តតិយជន ដែលអនុញ្ញាតឱ្យធ្វើអាជីវកម្មលើតក្កកម្មដែលបានទទួលប្រកាសនីយបត្រតក្កកម្មរួចហើយ រដ្ឋមន្ត្រីអាចធ្វើការផ្លាស់ប្តូរល័ក្ខខ័ណ្ឌនៃសេចក្តីសម្រេចដែលអនុញ្ញាតឱ្យធ្វើអាជីវកម្មលើតក្កកម្មខាងលើបាន ក្នុងកម្រិតដែលការផ្លាស់ប្តូរនោះ សមស្របតាមសភាពការណ៍ជាក់ស្តែង បន្ទាប់ពីបានស្តាប់យោបល់របស់ភាគីណាមួយ ឬភាគីទាំងពីរ ។

**មាត្រា ៤៩.-**

ផ្អែកតាមសំណើរបស់ម្ចាស់ប្រកាសនីយបត្រតក្កកម្ម និងក្រោយពីបានស្តាប់យោបល់របស់ភាគីណាមួយ ឬភាគីទាំងពីរ រដ្ឋមន្ត្រីអាចបញ្ចប់សេចក្តីអនុញ្ញាតឱ្យធ្វើអាជីវកម្មនោះបាន ក្នុងករណីដែលអង្គភាពរដ្ឋ ឬតតិយជនដែលបានជ្រើសរើសដោយរដ្ឋមន្ត្រី មិនបានបំពេញល័ក្ខខ័ណ្ឌនៃសេចក្តីសម្រេច ឬថាករណីនៃចំណុចទី ១ និងចំណុចទី ២

ដូចបានចែងក្នុងវាក្យខណ្ឌទី ១ នៃមាត្រា ៤៧ នៃច្បាប់នេះ លែងកើតមានទៀតហើយ ។

ថ្វីបើមានចែងនៅក្នុងវាក្យខណ្ឌទី ១ នៃមាត្រានេះក៏ដោយ ក៏រដ្ឋមន្ត្រីមិនត្រូវបញ្ចប់សេចក្ដីអនុញ្ញាតឱ្យធ្វើអាជីវកម្មនេះដែរ ប្រសិនបើពិនិត្យឃើញថាតម្រូវការសម្រាប់ការការពារផលប្រយោជន៍ស្របច្បាប់របស់អង្គភាពរដ្ឋ ឬតតិយជនដែលបានជ្រើសរើសដោយរដ្ឋមន្ត្រីត្រឹមត្រូវទៅតាមខ្លឹមសារដែលមានចែងក្នុងសេចក្ដីសម្រេច ។

**មាត្រា ៥០.-**

តតិយជនដែលត្រូវជ្រើសរើសដោយរដ្ឋមន្ត្រីឱ្យធ្វើអាជីវកម្ម អាចផ្ទេរសិទ្ធិធ្វើអាជីវកម្មបានជាមួយតែសហគ្រាស ឬក្រុមហ៊ុន ឬមួយផ្នែកនៃសហគ្រាស ឬក្រុមហ៊ុនរបស់តតិយជន ដែលកំពុងធ្វើអាជីវកម្មលើតក្កកម្មនោះ ។

**មាត្រា ៥១.-**

សេចក្ដីអនុញ្ញាតឱ្យធ្វើអាជីវកម្មត្រូវមានជាចាំបាច់ :

១-ការចុះកិច្ចសន្យាអាជ្ញាប័ណ្ណ ដែលធ្វើឡើងដោយម្ចាស់ប្រកាសនីយបត្រតក្កកម្ម ឬការអនុវត្តន៍បន្តសិទ្ធិធ្វើអាជីវកម្ម ដោយម្ចាស់ប្រកាសនីយបត្រតក្កកម្មដូចមានចែងក្នុងមាត្រា ៤២ នៃច្បាប់នេះ

២-ការចេញអាជ្ញាប័ណ្ណបញ្ជា ដូចមានចែងក្នុងផ្នែកទី ១២ នៃជំពូកទី ២ នៃច្បាប់នេះ ។

**មាត្រា ៥២.-**

សំណើសុំសេចក្ដីអនុញ្ញាតធ្វើអាជីវកម្មពីរដ្ឋមន្ត្រី ត្រូវតែភ្ជាប់មកជាមួយនូវភស្តុតាងបញ្ជាក់ថា ម្ចាស់ប្រកាសនីយបត្រតក្កកម្ម បានទទួលសំណើសុំចុះកិច្ចសន្យាអាជ្ញាប័ណ្ណពីបុគ្គលដែលចង់បានសិទ្ធិធ្វើអាជីវកម្ម តែបុគ្គលនោះមិនអាចទទួលកិច្ចសន្យាអាជ្ញាប័ណ្ណនោះបានលើបែបបទពាណិជ្ជកម្ម ល័ក្ខខ័ណ្ឌផ្សេងៗ និងពេលវេលាសមស្រប។

វាក្យខណ្ឌទី ១ នៃមាត្រានេះមិនត្រូវយកមកអនុវត្តទេ ក្នុងករណី :

**ក**-ប្រទេសជាតិមានភាពអាសន្ន ឬកាលៈទេសៈដទៃទៀតដែលកើតឡើងជាបន្ទាន់បំផុត ។ តែទោះជាយ៉ាងណាក៏ដោយ រដ្ឋមន្ត្រីត្រូវជូនដំណឹងអំពីសេចក្ដីសម្រេចនេះយ៉ាងឆាប់រហ័សដែលអាចធ្វើទៅបានដល់ម្ចាស់ប្រកាសនីយបត្រតក្កកម្ម ។

**ខ**-ការប្រើប្រាស់ជាសាធារណៈ មិនមានលក្ខណៈពាណិជ្ជកម្ម ។

**គ**-ការធ្វើអាជីវកម្ម មានលក្ខណៈប្រឆាំងនឹងការប្រកួតប្រជែងដូចមានចែងនៅក្នុងមាត្រា ៤៧ នៃច្បាប់នេះ ។

**មាត្រា ៥៣.-**

ការធ្វើអាជីវកម្មលើតក្កកម្ម ដោយអង្គភាពរដ្ឋ ឬដោយតតិយជនដែលបានជ្រើសរើសដោយរដ្ឋមន្ត្រី គឺសម្រាប់ផ្គត់ផ្គង់ឱ្យបានបរិបូរណ៍ដល់ទីផ្សារក្នុងព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ៥៤.-**

ការផ្តល់ការអនុញ្ញាតឱ្យអង្គភាពរដ្ឋ ឬតតិយជនធ្វើអាជីវកម្ម លើតក្កកម្ម ក្នុងវិស័យបច្ចេកវិជ្ជាសីមីខុនដាក់ទ័រ ដែលបានទទួលប្រកាស-នីយបត្រតក្កកម្មរួចហើយ គឺសម្រាប់តែការប្រើប្រាស់ជាសាធារណៈ ដែលមិនមានលក្ខណៈពាណិជ្ជកម្មតែប៉ុណ្ណោះ ។

ក្នុងករណី ដែលតុលាការមានសមត្ថកិច្ចបានវិនិច្ឆ័យថារបៀប ធ្វើអាជីវកម្មលើតក្កកម្មក្នុងវិស័យបច្ចេកវិជ្ជាសីមីខុនដាក់ទ័រនោះដោយ ម្ចាស់ដើម ឬដោយអ្នកទទួលអាជ្ញាប័ណ្ណមានលក្ខណៈប្រឆាំងនឹងការ ប្រកួតប្រជែង រដ្ឋមន្ត្រីអាចចេញអាជ្ញាប័ណ្ណបញ្ជាដើម្បីកែតម្រូវ របៀបធ្វើអាជីវកម្មនេះ ។

**មាត្រា ៥៥.-**

សេចក្តីសម្រេចរបស់រដ្ឋមន្ត្រី នៅក្នុងផ្នែកទី ១១ នៃជំពូកទី ២ នៃច្បាប់នេះ អាចជាកម្មវត្ថុសម្រាប់ប្តឹងតវ៉ាទៅតុលាការមានសមត្ថកិច្ច បាន ។

## ផ្នែកទី ១២
## អាជ្ញាប័ណ្ណបញ្ជា

**មាត្រា ៥៦.-**

នៅពេលដែលមានការស្នើសុំទៅរដ្ឋមន្ត្រី ក្រោយរយៈពេល បួន(៤)ឆ្នាំគិត ពីកាលបរិច្ឆេទសុំចុះបញ្ជីនៃការស្នើសុំប្រកាសនីយបត្រ-តក្កកម្ម ឬបី(៣)ឆ្នាំ គិតពីកាលបរិច្ឆេទផ្តល់ប្រកាសនីយបត្រតក្កកម្ម

ដោយយកកាលបរិច្ឆេទមួយណាដែលផុតកំណត់ក្រោយគេ រដ្ឋមន្ត្រីអាចចេញអាជ្ញាប័ណ្ណបញ្ហាបាន ប្រសិនបើរដ្ឋមន្ត្រីពិនិត្យឃើញថាតក្កកម្មដែលបានផ្តល់ប្រកាសនីយបត្រតក្កកម្មរួចហើយនោះ មិនត្រូវបានធ្វើអាជីវកម្ម ឬក៏ធ្វើអាជីវកម្មមិនពេញលេញ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

ថ្វីបើមានចែងនៅក្នុងវាក្យខណ្ឌទី ១ នៃមាត្រានេះក៏ដោយ អាជ្ញាប័ណ្ណបញ្ហាមិនត្រូវបានចេញទេ ប្រសិនបើម្ចាស់ប្រកាសនីយ-បត្រតក្កកម្មបានបំភ្លឺជូនរដ្ឋមន្ត្រីនូវកាលៈទេសៈសមស្របជាក់ស្តែងដែលបង្ហាញភស្តុតាងត្រឹមត្រូវពីការមិនបានធ្វើអាជីវកម្ម ឬការធ្វើអាជីវកម្មមិនពេញលេញ ។

**មាត្រា ៥៧.-**

ការសម្រេចចេញអាជ្ញាប័ណ្ណបញ្ហាត្រូវមានចែងអំពី :

១-វិសាលភាព និងមុខងារនៃអាជ្ញាប័ណ្ណ

២-ពេលវេលាកំណត់ដែលអ្នកទទួលអាជ្ញាប័ណ្ណ ត្រូវចាប់ផ្តើមធ្វើអាជីវកម្មលើតក្កកម្ម ដែលបានទទួលប្រកាសនីយបត្រ-តក្កកម្មរួចហើយ

៣-ចំនួនប្រាក់កម្រៃសមរម្យជូនទៅម្ចាស់ប្រកាសនីយ-បត្រតក្កកម្ម និងល័ក្ខខ័ណ្ឌនៃការទូទាត់ ។

**មាត្រា ៥៨.-**

អ្នកទទួលអាជ្ញាប័ណ្ណបញ្ហាមានសិទ្ធិធ្វើអាជីវកម្មលើតក្កកម្ម

ដែលបានទទួលប្រកាសនីយបត្រតក្កកម្មរួចហើយ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ទៅតាមល័ក្ខខ័ណ្ឌដែលបានចែងនៅក្នុងសេចក្តីសម្រេចនៃការចេញអាជ្ញាប័ណ្ណនោះ ។ អ្នកទទួលអាជ្ញាប័ណ្ណបញ្ជា ត្រូវចាប់ផ្តើមធ្វើអាជីវកម្មលើតក្កកម្មនោះ ទៅតាមពេលវេលាដែលបានកំណត់នៅក្នុងសេចក្តីសម្រេចខាងលើ និងត្រូវធ្វើអាជីវកម្មឱ្យបានពេញលេញលើតក្កកម្មនោះ ។

**មាត្រា ៥៩.-**

នៅពេលមានសំណើពីម្ចាស់ប្រកាសនីយបត្រតក្កកម្មក្រោយ រដ្ឋមន្ត្រីអាចចេញអាជ្ញាប័ណ្ណបញ្ជាដើម្បីបញ្ចៀសការធ្វើអាជីវកម្មនៅក្នុងប្រទេសរំលោភលើប្រកាសនីយបត្រតក្កកម្មមុន ក្នុងករណីតក្កកម្មដែលបានអះអាងនៅក្នុងប្រកាសនីយបត្រតក្កកម្មក្រោយនោះ មានការប្រើប្រាស់បច្ចេកទេសជឿនលឿនដែលបានចាត់ទុកថាមានសារៈសំខាន់ចំពោះសេដ្ឋកិច្ច ធៀបទៅនឹងតក្កកម្មដែលបានអះអាងនៅក្នុងប្រកាសនីយបត្រតក្កកម្មមុន ។

**មាត្រា ៦០.-**

ក្នុងករណីដែលអាជ្ញាប័ណ្ណបញ្ជា ត្រូវបានចេញឱ្យដូចមានចែងនៅក្នុងមាត្រា ៥៩ នៃច្បាប់នេះ នៅពេលមានសំណើពីម្ចាស់ប្រកាសនីយបត្រតក្កកម្មមុន រដ្ឋមន្ត្រីត្រូវចេញអាជ្ញាប័ណ្ណបញ្ជាមួយទៀតឱ្យប្រើប្រាស់ប្រកាសនីយបត្រតក្កកម្មក្រោយ ។

## មាត្រា ៦១.-

ក្នុងករណីមានសំណើសុំអាជ្ញាប័ណ្ណបញ្ជា ដូចមានចែងក្នុងមាត្រា ៥៩ និងមាត្រា ៦០ នោះ មាត្រា ៥៧ នៃច្បាប់នេះ ត្រូវយកមកអនុវត្តជាមួយនឹងល័ក្ខខ័ណ្ឌនៃកិច្ចព្រមព្រៀងដោយមិនចាំបាច់បញ្ជាក់ពីពេលវេលាកំណត់ទេ ។

## មាត្រា ៦២.-

ក្នុងករណីចេញអាជ្ញាប័ណ្ណបញ្ជា ដែលមានចែងក្នុងមាត្រា ៥៩ នៃច្បាប់នេះ ការផ្ទេរសិទ្ធិធ្វើអាជីវកម្មអាចធ្វើបានតែជាមួយនឹងប្រកាស-នីយបត្រតក្កកម្មក្រោយតែប៉ុណ្ណោះ ឬក្នុងករណីចេញអាជ្ញាប័ណ្ណបញ្ជាដែលមានចែងក្នុងមាត្រា ៦០ នៃច្បាប់នេះ ការផ្ទេរសិទ្ធិធ្វើអាជីវកម្មអាចធ្វើបានតែជាមួយនឹងប្រកាសនីយបត្រតក្កកម្មមុនតែប៉ុណ្ណោះ ។

## មាត្រា ៦៣.-

ការស្នើសុំអាជ្ញាប័ណ្ណបញ្ជាត្រូវបង់កម្រៃតាមការកំណត់ ដូចមានចែងក្នុងមាត្រា ១៣០ នៃច្បាប់នេះ ។

## មាត្រា ៦៤.-

ខ្លឹមសារទាំងឡាយដែលមានចែងនៅក្នុងវាក្យខណ្ឌទី ២ នៃមាត្រា ៤៧ ដល់មាត្រា ៥៥ នៃច្បាប់នេះ ត្រូវយកមកអនុវត្តនៅក្នុងផ្នែកទី ១២ នៃជំពូកទី ២ នៃច្បាប់នេះ ។

## ផ្នែកទី ១៣

## មោឃភាព

### មាត្រា ៦៥.-

បុគ្គលដែលមានការពាក់ព័ន្ធ អាចស្នើសុំទៅតុលាការមានសមត្ថកិច្ច ឱ្យទុកជាមោឃៈនូវប្រកាសនីយបត្រតក្កកម្មបាន ។

### មាត្រា ៦៦.-

តុលាការមានសមត្ថកិច្ច ត្រូវចាត់ទុកជាមោឃៈនូវប្រកាសនីយបត្រតក្កកម្ម ប្រសិនបើបុគ្គលដែលស្នើសុំនូវមោឃភាពនោះ បានបង្ហាញភស្តុតាងថាល័ក្ខខ័ណ្ឌតម្រូវណាមួយនៃវាក្យខណ្ឌទី ២ និងទី ៣ នៃមាត្រា ៣ មាត្រា ៤ ដល់មាត្រា ៩ និងមាត្រា ១៨ ដល់មាត្រា ២០ នៃច្បាប់នេះ មិនត្រូវបានបំពេញគ្រប់គ្រាន់ ឬប្រសិនបើម្ចាស់ប្រកាស-នីយបត្រតក្កកម្មមិនមែនជាតក្កករ ឬមិនមែនជាអ្នកស្នងរបស់តក្កករ ។

### មាត្រា ៦៧.-

ចំពោះប្រកាសនីយបត្រតក្កកម្មដែលត្រូវបានចាត់ទុកជាមោឃៈ ឬសេចក្ដីអះអាង ឬផ្នែកនៃសេចក្ដីអះអាងដែលត្រូវចាត់ទុកថាមិនបានការ ត្រូវអស់សុពលភាពចាប់ពីថ្ងៃដែលផ្ដល់ប្រកាសនីយបត្រតក្កកម្មមក ។

### មាត្រា ៦៨.-

សេចក្ដីសម្រេចជាស្ថាពររបស់តុលាការមានសមត្ថកិច្ចត្រូវបាន

ជូនដំណឹងដល់មន្ត្រីកាន់កាប់បញ្ជី ដើម្បីឱ្យមន្ត្រីកាន់កាប់បញ្ជីកត់ត្រា និងចុះផ្សាយសេចក្តីសម្រេចរបស់តុលាការឱ្យបានឆាប់រហ័សតាមលទ្ធភាពដែលអាចធ្វើទៅបាន ។

## ជំពូកទី ៣
## វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍

### ផ្នែកទី ១
### វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ដែលអាចការពារបាន

**មាត្រា ៦៩.-**

ក្នុងន័យនៃច្បាប់នេះ វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ គឺជាវិញ្ញាបនបត្រដែលបានផ្តល់ដើម្បីការពារម៉ូដែលមានអត្ថប្រយោជន៍ ។ ម៉ូដែលមានអត្ថប្រយោជន៍គឺជាតក្កកម្មណាមួយដែលថ្មី និងអាចយកទៅអនុវត្តបានក្នុងវិស័យឧស្សាហកម្ម និងដែលអាចជាផលិតផល ឬដំណើរការផលិតកម្ម ឬដែលអាចទាក់ទងទៅនឹងផលិតផល ឬដំណើរការផលិតកម្ម ។

### ផ្នែកទី ២
### ការអនុវត្តន៍បទប្បញ្ញត្តិ
### ពាក់ព័ន្ធនឹងប្រកាសនីយបត្រតក្កកម្ម

**មាត្រា ៧០.-**

បទប្បញ្ញត្តិទាំងឡាយនៃជំពូកទី ២ នៃច្បាប់នេះ ត្រូវយកមកអនុវត្តចំពោះ វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ ឬចំពោះ

សំណុំលិខិតស្នើសុំវិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ លើកលែងតែមាត្រា ៧១ ដល់មាត្រា ៧៤ នៃច្បាប់នេះ ។

ក្នុងករណីមានទំនាស់រវាងសិទ្ធិលើប្រកាសនីយបត្រតក្កកម្ម និងសិទ្ធិលើវិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ ដូចបានចែងនៅក្នុងផ្នែកទី ២ នៃជំពូកទី ២នៃច្បាប់នេះ បទប្បញ្ញត្តិចែងក្នុងវាក្យខណ្ឌខាងលើត្រូវយកមកអនុវត្ត ដោយគ្រាន់តែជំនួសពាក្យប្រកាសនីយបត្រតក្កកម្ម ដោយពាក្យប្រកាសនីយបត្រតក្កកម្មវិញ ឬពាក្យវិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ ។

## ផ្នែកទី ៣
## បទប្បញ្ញត្តិពិសេស
## ពាក់ព័ន្ធនឹងវិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍

**មាត្រា ៧១.-**

មាត្រា ៥ និងមាត្រា ៧ នៃច្បាប់នេះ មិនត្រូវយកមកអនុវត្តទេ ក្នុងករណីដែលតក្កកម្មត្រូវបានស្នើសុំផ្តល់វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ ។

**មាត្រា ៧២.-**

មាត្រា ៣៦ និងមាត្រា ៤៥ នៃច្បាប់នេះ មិនត្រូវយកមកអនុវត្តទេ ចំពោះសំណុំលិខិតស្នើសុំផ្តល់វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ ។

**មាត្រា ៧៣.-**

វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ មានសុពលភាពរយៈពេលប្រាំពីរ(៧)ឆ្នាំ គិតចាប់ពីកាលបរិច្ឆេទសុំចុះបញ្ជីស្នើសុំវិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ដោយមិនមានការផ្តល់ជាថ្មីឡើងវិញឡើយ ។

**មាត្រា ៧៤.-**

អនុលោមតាមមាត្រា ៦៥ ដល់មាត្រា ៦៧ នៃច្បាប់នេះ តុលាការមានសមត្ថកិច្ច ត្រូវចាត់ទុកជាមោឃៈនូវវិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ ដោយមូលហេតុណាមួយដូចខាងក្រោម :

១-តក្កកម្មដែលអះអាងនោះ មិនបំពេញតាមល័ក្ខខ័ណ្ឌតម្រូវរបស់វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ ដោយយោងតាមមាត្រា ៦ មាត្រា ៨ មាត្រា ៩ និងមាត្រា ៦៩ នៃច្បាប់នេះ ។

២-សេចក្តីអធិប្បាយនិងសេចក្តីអះអាងមិនបានបំពេញតាមល័ក្ខខ័ណ្ឌតម្រូវដែលមានចែងក្នុងមាត្រា ១៨ និងមាត្រា ១៩ នៃច្បាប់នេះ និងបទបញ្ញាដែលពាក់ព័ន្ធនឹងមាត្រាទាំងនោះ ។

៣-គំនូសបង្ហាញដែលត្រូវការចាំបាច់សម្រាប់ពន្យល់អំពីតក្កកម្មមិនត្រូវបានផ្តល់ឱ្យតាមល័ក្ខខ័ណ្ឌតម្រូវ ។

៤-ម្ចាស់វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍មិនមែនជាតក្កករ ឬមិនមែនជាអ្នកស្នងរបស់តក្កករ ។

## ផ្នែកទី ៤
## ការផ្លាស់ប្តូរសំណុំលិខិតស្នើសុំប្រកាសនីយបត្រតក្កកម្ម ឬសំណុំលិខិតស្នើសុំវិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍

**មាត្រា ៧៥.-**

មុនពេលផ្តល់ ឬបដិសេធការផ្តល់ប្រកាសនីយបត្រតក្កកម្ម អ្នកដាក់ពាក្យសុំអាចផ្លាស់ប្តូរសំណុំលិខិតស្នើសុំប្រកាសនីយបត្រតក្កកម្មរបស់ខ្លួន ទៅជាសំណុំលិខិតស្នើសុំវិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍បាន ដោយត្រូវបង់កម្រៃតាមការកំណត់ដូចមានចែងក្នុងមាត្រា ១៣០ នៃច្បាប់នេះ ។ កាលបរិច្ឆេទសុំចុះបញ្ជីស្នើសុំវិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍នោះ ត្រូវបានកត់ត្រាទៅតាមកាលបរិច្ឆេទសុំចុះបញ្ជីស្នើសុំប្រកាសនីយបត្រតក្កកម្ម ។

មុនពេលផ្តល់ ឬបដិសេធការផ្តល់វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ អ្នកដាក់ពាក្យសុំអាចផ្លាស់ប្តូរសំណុំលិខិតស្នើសុំវិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍របស់ខ្លួន ទៅជាសំណុំលិខិតស្នើសុំប្រកាសនីយបត្រតក្កកម្មបានដោយត្រូវបង់កម្រៃតាមការកំណត់ដូចមានចែងក្នុងមាត្រា ១៣០ នៃច្បាប់នេះ ។ កាលបរិច្ឆេទសុំចុះបញ្ជីស្នើសុំប្រកាសនីយបត្រតក្កកម្មនោះ ត្រូវបានកត់ត្រាទៅតាមកាលបរិច្ឆេទសុំចុះបញ្ជីស្នើសុំវិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ ។

**មាត្រា ៧៦.-**

អនុលោមតាមមាត្រា ៧៥ នៃច្បាប់នេះ ការផ្លាស់ប្តូរសំណុំលិខិតស្នើសុំធ្វើបានតែមួយដងប៉ុណ្ណោះ ។

# ជំពូកទី ៤

# សំណុំលិខិតស្នើសុំអន្តរជាតិ ក្រោមសន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្ម

## ផ្នែកទី ១

## ការបកស្រាយនៃវាក្យស័ព្ទពាក់ព័ន្ធនឹងសន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្ម

**មាត្រា ៧៧.-**

ក្នុងន័យនៃច្បាប់នេះ :

១-សន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្ម មានន័យថាជាសន្ធិសញ្ញាស្តីពីកិច្ចសហប្រតិបត្តិការលើវិស័យប្រកាស-នីយបត្រតក្កកម្ម ដែលបានចុះហត្ថលេខានៅថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ១៩៧០ នៅទីក្រុងវ៉ាស៊ីងតោន ។

២-ពាក្យ : ជ្រើសរើស ការិយាល័យជ្រើសរើស ជ្រើសតាំង ការិយាល័យជ្រើសតាំង សំណុំលិខិតស្នើសុំអន្តរជាតិ កាលបរិច្ឆេទសុំចុះបញ្ជីសំណុំលិខិតស្នើសុំអន្តរជាតិ ការពិនិត្យជំហានដំបូងអន្តរជាតិ និងការិយាល័យទទួលសំណុំលិខិតស្នើសុំ មានន័យដូចមានចែងនៅក្នុងសន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្ម ។

## ផ្នែកទី ២
## កាលបរិច្ឆេទសុំចុះបញ្ជី
## និងអានុភាពនៃសំណុំលិខិតស្នើសុំអន្តរជាតិ
## ដែលព្រះរាជាណាចក្រកម្ពុជា ជាប្រទេសដែលត្រូវបានជ្រើសរើស

**មាត្រា ៧៨.-**

យោងតាមជំពូកនេះ សំណុំលិខិតស្នើសុំអន្តរជាតិដែលព្រះរាជាណាចក្រកម្ពុជាជាប្រទេសដែលត្រូវបានជ្រើសរើស ត្រូវចាត់ទុកថាជាសំណុំលិខិតស្នើសុំប្រកាសនីយបត្រតក្កកម្ម ឬវិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ដែលបានសុំចុះបញ្ជីនៅក្រោមច្បាប់នេះ ដោយមានកាលបរិច្ឆេទសុំចុះបញ្ជីដូចគ្នា ទៅនឹងកាលបរិច្ឆេទសុំចុះបញ្ជីអន្តរជាតិដូចបានចែងនៅក្នុងសន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្ម ។

## ផ្នែកទី ៣
## នាយកដ្ឋានទទួលបន្ទុកចុះបញ្ជីដែលអនុវត្តតួនាទី
## ជាការិយាល័យទទួលសំណុំលិខិតស្នើសុំ

**មាត្រា ៧៩.-**

នាយកដ្ឋានទទួលបន្ទុកចុះបញ្ជី ត្រូវអនុវត្តតួនាទីជាការិយាល័យទទួលសំណុំលិខិតស្នើសុំ ចំពោះសំណុំលិខិតស្នើសុំអន្តរជាតិ ដែលបានដាក់នៅនាយកដ្ឋានទទួលបន្ទុកចុះបញ្ជីដោយជនដែលមានទីលំនៅនៅក្នុងព្រះរាជាណាចក្រកម្ពុជា ឬជនដែលមានសញ្ជាតិខ្មែរ ។

**មាត្រា ៨០.-**

រដ្ឋមន្ត្រីអាចចុះកិច្ចព្រមព្រៀងបាន ដោយយោងទៅតាមវិធាន ១៩.១(ខ)នៃបទប្បញ្ញត្តិរបស់សន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយ-បត្រតក្កកម្ម ដែលតាមរយៈនោះ អង្គការអន្តររដ្ឋាភិបាល ឬ ការិយាល័យជាតិនៃរដ្ឋ ដែលជាសមាជិកសន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្ម ត្រូវអនុវត្តតួនាទីជាការិយាល័យទទួលសំណុំលិខិតស្នើសុំជំនួសនាយកដ្ឋានទទួលបន្ទុកចុះបញ្ជី សម្រាប់អ្នកដាក់ពាក្យសុំជាជនដែលមានទីលំនៅ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ឬ ជនដែលមានសញ្ញាតិខ្មែរ ។

## ផ្នែកទី ៤
## ការដាក់សំណុំលិខិតស្នើសុំអន្តរជាតិ
## នៅនាយកដ្ឋានទទួលបន្ទុកចុះបញ្ជី

**មាត្រា ៨១.-**

សំណុំលិខិតស្នើសុំអន្តរជាតិដែលត្រូវដាក់នៅនាយកដ្ឋានទទួលបន្ទុកចុះបញ្ជីក្នុងតួនាទីជាការិយាល័យទទួលសំណុំលិខិតស្នើសុំនោះ ត្រូវធ្វើជាភាសាណាមួយដែលបានកំណត់ ។ កម្រៃក្នុងការបញ្ជូនឯកសារត្រូវបង់នៅនាយកដ្ឋានទទួលបន្ទុកចុះបញ្ជីតាមការកំណត់ដូចមានចែងក្នុងមាត្រា ១៣០ នៃច្បាប់នេះ ។

## ផ្នែកទី ៥
## នាយកដ្ឋានទទួលបន្ទុកចុះបញ្ជី
## ដែលអនុវត្តតួនាទីជាការិយាល័យជ្រើសរើស

**មាត្រា ៨២.-**

នាយកដ្ឋានទទួលបន្ទុកចុះបញ្ជី ត្រូវបំពេញតួនាទីជាការិយាល័យជ្រើសរើសចំពោះសំណុំលិខិតស្នើសុំអន្តរជាតិ ដែលព្រះរាជាណាចក្រកម្ពុជា ត្រូវបានជ្រើសរើសដោយយោងតាមជំពូកទី ១ នៃសន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្ម ក្នុងគោលបំណងទទួលបាននូវប្រកាសនីយបត្រតក្កកម្ម ឬវិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍កម្រិតជាតិនៅក្រោមច្បាប់នេះ ។

## ផ្នែកទី ៦
## នាយកដ្ឋានទទួលបន្ទុកចុះបញ្ជី
## ដែលអនុវត្តតួនាទីជាការិយាល័យជ្រើសតាំង

**មាត្រា ៨៣.-**

នាយកដ្ឋានទទួលបន្ទុកចុះបញ្ជី ត្រូវបំពេញតួនាទីជាការិយាល័យជ្រើសតាំងចំពោះសំណុំលិខិតស្នើសុំអន្តរជាតិ ដែលព្រះរាជាណាចក្រកម្ពុជា ត្រូវបានជ្រើសរើសយោងតាមមាត្រា ៨២ នៃច្បាប់នេះ ប្រសិនបើអ្នកដាក់ពាក្យសុំជ្រើសតាំងព្រះរាជាណាចក្រកម្ពុជា ដោយយោងតាមជំពូកទី ២ នៃសន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្ម ក្នុងគោលបំណងទទួលបាននូវប្រកាសនីយ-បត្រតក្កកម្ម ឬវិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍កម្រិតជាតិ

នៅក្រោមច្បាប់នេះ ។

## ផ្នែកទី ៧
## កិច្ចដំណើរការពិនិត្យកម្រិតជាតិ

**មាត្រា ៨៤.-**

នាយកដ្ឋានទទួលបន្ទុកចុះបញ្ជី ដែលជាការិយាល័យជ្រើសរើស ឬការិយាល័យជ្រើសតាំង មិនត្រូវចាប់ដំណើរការពិនិត្យសំណុំលិខិតស្នើសុំអន្តរជាតិដែលបានជ្រើសរើសព្រះរាជាណាចក្រកម្ពុជា មុនរយៈពេលផុតកំណត់ដូចបានចែងក្នុងមាត្រា ៨៥ នៃច្បាប់នេះទេ លើកលែងតែអ្នកដាក់ពាក្យសុំបានបំពេញតាមល័ក្ខខ័ណ្ឌតម្រូវនៃមាត្រានោះហើយដាក់នូវសំណើជាការប្រញាប់មកនាយកដ្ឋានទទួលបន្ទុកចុះបញ្ជី ដើម្បីឱ្យចាប់ផ្តើមពិនិត្យសំណុំលិខិតស្នើសុំមុនរយៈពេលកំណត់។

## ផ្នែកទី ៨
## ការឈានចូលដំណាក់ការពិនិត្យកម្រិតជាតិ

**មាត្រា ៨៥.-**

មុនផុតរយៈពេលកំណត់ ដែលមានចែងក្នុងមាត្រា ២២ ឬមាត្រា ៣៩ នៃសន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្ម ឬរយៈពេលកំណត់ចុងក្រោយដែលមានចែងនៅក្នុងបទបញ្ញានៃច្បាប់នេះ អ្នកដាក់សំណុំលិខិតស្នើសុំអន្តរជាតិនៅព្រះរាជាណាចក្រកម្ពុជាត្រូវ :

១-បង់កម្រៃតាមការកំណត់ដូចមានចែងក្នុងមាត្រា ១៣០ នៃច្បាប់នេះនៅនាយកដ្ឋានទទួលបន្ទុកចុះបញ្ជី

២-ដាក់ជូននាយកដ្ឋានទទួលបន្ទុកចុះបញ្ជីនូវសេចក្ដីបកប្រែនៃសំណុំលិខិតស្នើសុំអន្តរជាតិជាភាសាណាមួយតាមការកំណត់ ប្រសិនបើសំណុំលិខិតស្នើសុំអន្តរជាតិនោះមិនបានដាក់ជូនជាភាសាដែលបានកំណត់ ឬមិនបានចុះផ្សាយក្រោមសន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្មនូវការបកប្រែជាភាសាដែលបានកំណត់នោះ ។

## ផ្នែកទី ៩
## ការខកខានមិនបានឈានចូល
## ដំណាក់ការពិនិត្យកម្រិតជាតិ

**មាត្រា ៨៦.-**

ក្នុងន័យនៃច្បាប់នេះ ប្រសិនបើអ្នកដាក់ពាក្យសុំមិនបានបំពេញតាមល័ក្ខខ័ណ្ឌតម្រូវ និងតាមរយៈពេលកំណត់ នៃមាត្រា ៨៥ នៃច្បាប់នេះទេ សំណុំលិខិតស្នើសុំអន្តរជាតិនោះនឹងត្រូវបានចាត់ទុកថាបានដកយកទៅវិញ ។

## ផ្នែកទី ១០
## កិច្ចដំណើរការពិនិត្យ
## សំណុំលិខិតស្នើសុំអន្តរជាតិអនុលោមតាម
## សន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្ម

**មាត្រា ៨៧.-**

នាយកដ្ឋានទទួលបន្ទុកចុះបញ្ជីត្រូវដំណើរការពិនិត្យសំណុំ

លិខិតស្នើសុំអន្តរជាតិ ដោយអនុលោមតាមបទប្បញ្ញត្តិនៃសន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្ម ព្រមទាំងអនុលោមតាមបទប្បញ្ញត្តិនៃច្បាប់នេះ ។ នៅពេលមានទំនាស់កើតឡើង ត្រូវយកបទប្បញ្ញត្តិនៃសន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្ម មកអនុវត្តបទបញ្ញាទាំងឡាយដែលបង្កើតឡើងនៅក្រោមច្បាប់នេះត្រូវបានចែងឡើងសម្រាប់កិច្ចដំណើរការពិនិត្យសំណុំលិខិតស្នើសុំអន្តរជាតិ ។

**មាត្រា ៨៨.-**

ការពិនិត្យសំណុំលិខិតស្នើសុំអន្តរជាតិ ដោយនាយកដ្ឋានទទួលបន្ទុកចុះបញ្ជីនិងការប្រព្រឹត្តិទៅនៃនាយកដ្ឋាននេះដែលទាក់ទងជាមួយនឹងសន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្ម រួមទាំងកម្រៃដែលត្រូវបង់ ការកំណត់ពេលវេលានិងល័ក្ខខ័ណ្ឌតម្រូវផ្សេងៗដែលពាក់ព័ន្ធទៅនឹងសំណុំលិខិតស្នើសុំអន្តរជាតិ ត្រូវកំណត់ដោយបទបញ្ញានិងត្រូវអនុវត្តតាមមាត្រា ១៣០ នៃច្បាប់នេះ ។

## ជំពូកទី ៥

## គំនូរឧស្សាហកម្ម

### ផ្នែកទី ១

### គំនូរឧស្សាហកម្មដែលអាចការពារបាន

**មាត្រា ៨៩.-**

គំនូរឧស្សាហកម្ម ក្នុងន័យនៃច្បាប់នេះ គឺជាការផ្គុំនៃបន្ទាត់ ឬពណ៌ ឬទម្រង់បីខ្នាត ឬសម្ភារៈណាមួយ ទោះបីជាមានឬពុំមានការ

ផ្គុំរួមជាមួយបន្ទាត់ ឬពណ៌ក៏ដោយឱ្យតែការផ្គុំទម្រង់ ឬសម្ភារៈទាំងនោះរំលេចឡើងជារូបរាងពិសេសរបស់ផលិតផលឧស្សាហកម្ម ឬសិប្បកម្ម និងដែលអាចធ្វើជាគំរូផលិតផលឧស្សាហកម្ម ឬសិប្បកម្ម និងអាចសម្គាល់បានដោយចក្ខុ ។

**មាត្រា ៩០.-**

ច្បាប់នេះមិនការពារផ្នែកណាមួយនៃគំនូរឧស្សាហកម្ម ដែលបម្រើឱ្យគោលបំណងសម្រាប់តែទទួលបាននូវលទ្ធផលបច្ចេកទេស និងដែលផ្នែកនោះមិនមានរូបរាងច្បាស់លាស់ ។

## ផ្នែកទី ២

## គំនូរឧស្សាហកម្មដែលអាចចុះបញ្ជីបាន

**មាត្រា ៩១.-**

គំនូរឧស្សាហកម្មអាចចុះបញ្ជីបាន ប្រសិនបើថ្មី ។

**មាត្រា ៩២.-**

គំនូរឧស្សាហកម្មត្រូវចាត់ថាថ្មី ប្រសិនបើគំនូរឧស្សាហកម្មនោះមិនទាន់បានបញ្ចេញឱ្យដឹងដល់សាធារណជននៅទីកន្លែងណាមួយនៅលើពិភពលោក មុនកាលបរិច្ឆេទសុំចុះបញ្ជី ឬមុនកាលបរិច្ឆេទអាទិភាពនៃសំណុំលិខិតស្នើសុំ តាមរយៈការផ្សព្វផ្សាយដោយប្រើរូបភាពជាក់ស្តែង ឬតាមរយៈការប្រើប្រាស់ ឬតាមរយៈមធ្យោបាយផ្សព្វផ្សាយផ្សេងៗទៀត ។

ក្នុងន័យនៃវាក្យខណ្ឌទី ១ នៃមាត្រានេះ មិនបានចាត់ទុកថាជាការដឹងដល់សាធារណជនចំពោះករណីដូចខាងក្រោម :

**ក**-ការដឹងដល់សាធារណជននូវគំនូរឧស្សាហកម្មដែលបានកើតឡើងក្នុងអំឡុងពេលដប់ពីរ(១២)ខែ មុនកាលបរិច្ឆេទសុំចុះបញ្ជីសំណុំលិខិតស្នើសុំ ឬកាលបរិច្ឆេទអាទិភាពនៃសំណុំលិខិតស្នើសុំនោះ

**ខ**-ការធ្វើឱ្យលេចឮខ្ចរខ្ចាយពត៌មានអំពីគំនូរឧស្សាហកម្មតាមរយៈអ្នកដាក់ពាក្យសុំ តាមរយៈអ្នកស្នងរបស់បុព្វជន ឬតាមរយៈការរំលោភរបស់ភាគីទីបីទៅលើអ្នកដាក់ពាក្យសុំ ឬអ្នកស្នងរបស់បុព្វជនដែលបណ្តាលឱ្យលេចឮខ្ចរខ្ចាយពត៌មាននេះ ។

**មាត្រា ៩៣.-**

គំនូរឧស្សាហកម្ម ដែលផ្ទុយនឹងសណ្តាប់ធ្នាប់សាធារណៈ ឬសីលធម៌មិនអាចចុះបញ្ជីបានឡើយ ។

## ផ្នែកទី ៣
## សិទ្ធិក្នុងការចុះបញ្ជីគំនូរឧស្សាហកម្ម និងការដាក់ឈ្មោះអ្នកបង្កើតស្នាដៃ

**មាត្រា ៩៤.-**

ខ្លឹមសារទាំងឡាយ ដែលមានចែងនៅក្នុងមាត្រា ១០ ដល់មាត្រា ១៥ នៃច្បាប់នេះ ត្រូវយកមកអនុវត្តនៅផ្នែកទី ៣ នៃជំពូកទី ៥ នៃច្បាប់នេះ ។

## ផ្នែកទី ៤
## សំណុំលិខិតស្នើសុំចុះបញ្ជីគំនូរឧស្សាហកម្ម

**មាត្រា ៩៥.-**

សំណុំលិខិតស្នើសុំចុះបញ្ជីគំនូរឧស្សាហកម្មត្រូវដាក់ជូនទៅក្រសួងទទួលបន្ទុកឧស្សាហកម្ម ដែលក្នុងនោះត្រូវរួមមានពាក្យសុំ គំនូសបង្ហាញ រូបថត ឬគំនូសតាងផ្សេងៗទៀត ជាតំណាងនៃវត្ថុដែលបង្កើតឡើងពីគំនូរឧស្សាហកម្ម និងការចង្អុលបង្ហាញប្រភេទផលិតផល ដែលគំនូរឧស្សាហកម្មត្រូវយកមកប្រើប្រាស់ ។ ក្នុងករណីដែលគំនូរឧស្សាហកម្មនោះមានទម្រង់ពីរខ្នាត សំណុំលិខិតស្នើសុំនេះត្រូវភ្ជាប់ដោយរូបសំណាកវត្ថុដែលតាងឱ្យរូបរាងពិតរបស់គំនូរឧស្សាហកម្ម ។ ការដាក់សំណុំលិខិតស្នើសុំត្រូវតែមានការបង់កម្រៃតាមការកំណត់ដូចមានចែងក្នុងមាត្រា១៣០នៃច្បាប់នេះ ។

**មាត្រា ៩៦.-**

ក្នុងករណីអ្នកដាក់ពាក្យសុំមិនមែនជាអ្នកបង្កើតស្នាដៃ ពាក្យសុំចុះបញ្ជីគំនូរឧស្សាហកម្មនោះត្រូវតែភ្ជាប់មកជាមួយនូវឯកសារបញ្ជាក់អំពីសិទ្ធិរបស់អ្នកដាក់ពាក្យសុំ ក្នុងការសុំចុះបញ្ជីគំនូរឧស្សាហកម្មនោះ។

**មាត្រា ៩៧.-**

គំនូរឧស្សាហកម្មពីរ ឬច្រើននៃវត្ថុដែលស្ថិតនៅក្នុងក្រុមជាមួយគ្នានៃចំណាត់ថ្នាក់អន្តរជាតិ ឬក្នុងឈុតជាមួយគ្នា ឬក៏ការផ្គុំដូចគ្នាអាចជាកម្មវត្ថុដើម្បីធ្វើសំណុំលិខិតស្នើសុំតែមួយបាន ។

**មាត្រា ៩៨.-**

ក្នុងករណីសំណុំលិខិតស្នើសុំចុះបញ្ជីគំនូរឧស្សាហកម្មមានភ្ជាប់ពាក្យសុំពន្យារការធ្វើការចុះផ្សាយគំនូរឧស្សាហកម្មនោះ អាចត្រូវពន្យារធ្វើការចុះផ្សាយបានតែមិនត្រូវលើសពីដប់ពីរ(១២)ខែ គិតពីកាលបរិច្ឆេទសុំចុះបញ្ជី ឬកាលបរិច្ឆេទអាទិភាព ។

**មាត្រា ៩៩.-**

អ្នកដាក់ពាក្យសុំចុះបញ្ជីគំនូរឧស្សាហកម្ម អាចដកសំណុំលិខិតស្នើសុំទៅវិញនៅពេលណាក៏បាន ក្នុងករណីដែលសំណុំលិខិតស្នើសុំនោះស្ថិតក្នុងរយៈពេលល្អរទុកសម្រាប់ពិនិត្យដើម្បីសម្រេចឱ្យចុះបញ្ជី ។

## ផ្នែកទី ៥
## សិទ្ធិអាទិភាព

**មាត្រា ១០០.-**

ខ្លឹមសារទាំងឡាយដែលមានចែងនៅក្នុងមាត្រា ២៧ ដល់មាត្រា ២៩ នៃច្បាប់នេះ ត្រូវយកមកអនុវត្តនៅផ្នែកទី ៥ នៃជំពូកទី ៥ នៃច្បាប់នេះ ។

## ផ្នែកទី ៦
## ការពិនិត្យ ការចុះបញ្ជី និងការចុះផ្សាយគំនូរឧស្សាហកម្ម

**មាត្រា ១០១.-**

មន្ត្រីកាន់កាប់បញ្ជីអាចទទួលស្គាល់កាលបរិច្ឆេទទទួលសំណុំ

លិខិតស្នើសុំថាជាកាលបរិច្ឆេទសុំចុះបញ្ជីបាន លុះត្រាតែនៅពេលទទួលនោះ សំណុំលិខិតមានអមដោយសេចក្ដីបញ្ជាក់ពីអត្តសញ្ញាណរបស់អ្នកដាក់ពាក្យសុំ និងមានបង្ហាញគំនូសតាងជាតំណាងនៃវត្ថុដែលបង្កើតដោយគំនូរឧស្សាហកម្មនោះ ។

នៅពេលបានទទួលសំណុំលិខិតស្នើសុំ ប្រសិនបើមន្ត្រីកាន់កាប់បញ្ជីពិនិត្យឃើញថាសំណុំលិខិតស្នើសុំនោះមិនបានបំពេញត្រឹមត្រូវទៅតាមល័ក្ខខ័ណ្ឌតម្រូវរបស់វាក្យខណ្ឌទី ១ នៃមាត្រានេះទេ មន្ត្រីកាន់កាប់បញ្ជីត្រូវស្នើឱ្យអ្នកដាក់ពាក្យសុំធ្វើការកែតម្រូវទៅតាមល័ក្ខខ័ណ្ឌតម្រូវនោះ និងកត់ត្រាកាលបរិច្ឆេទសុំចុះបញ្ជីទៅតាមកាលបរិច្ឆេទដែលបានទទួលការកែតម្រូវ ។ ប៉ុន្តែប្រសិនបើសំណុំលិខិតស្នើសុំមិនបានកែតម្រូវទៅតាមការណែនាំទេ សំណុំលិខិតស្នើសុំនោះមិនត្រូវទទួលចុះបញ្ជីឡើយ ។

**មាត្រា ១០២.-**

បន្ទាប់ពីការកត់ត្រាកាលបរិច្ឆេទសុំចុះបញ្ជី មន្ត្រីកាន់កាប់បញ្ជីត្រូវពិនិត្យលើ :

១-សំណុំលិខិតស្នើសុំចុះបញ្ជីបំពេញឱ្យបានត្រឹមត្រូវតាមល័ក្ខខ័ណ្ឌតម្រូវនៃមាត្រា ៩៥ និងមាត្រា ៩៦ នៃច្បាប់នេះ និងបទបញ្ញាដែលពាក់ព័ន្ធទៅនឹងមាត្រាទាំងនេះ ។

២-ការបង់កម្រៃក្នុងការដាក់សំណុំលិខិតស្នើសុំ ឱ្យបានត្រឹមត្រូវទៅតាមការកំណត់ដូចមានចែងក្នុងមាត្រា ១៣០ នៃច្បាប់នេះ ។

៣-គំនូរឧស្សាហកម្មបំពេញឱ្យ បានត្រឹមត្រូវតាមល័ក្ខខ័ណ្ឌតម្រូវនៃមាត្រា ៨៩ មាត្រា ៩០ មាត្រា ៩៣ នៃច្បាប់នេះ និងបទបញ្ញាដែលពាក់ព័ន្ធទៅនឹងមាត្រាទាំងនេះ ។

**មាត្រា ១០៣.-**

មន្ត្រីកាន់កាប់បញ្ជីត្រូវចុះបញ្ជីគំនូរឧស្សាហកម្ម ចុះផ្សាយសេចក្តីបញ្ជាក់អំពីការចុះបញ្ជី និងត្រូវដំណើរការចេញវិញ្ញាបនបត្រចុះបញ្ជីឱ្យអ្នកដាក់ពាក្យសុំ ប្រសិនបើពិនិត្យឃើញថាល័ក្ខខ័ណ្ឌទាំងឡាយដូចមានចែងនៅក្នុងមាត្រា ១០២ នៃច្បាប់នេះបានបំពេញត្រឹមត្រូវ ។ ក្នុងករណីសំណុំលិខិតស្នើសុំមិនបានបំពេញត្រឹមត្រូវមន្ត្រីកាន់កាប់បញ្ជីត្រូវធ្វើការបដិសេធសំណុំលិខិតស្នើសុំនោះ ។

**មាត្រា ១០៤.-**

មន្ត្រីកាន់កាប់បញ្ជីមិនត្រូវបើកបង្ហាញជាសាធារណៈនូវគំនូរឬឯកសារណាមួយដែលពាក់ព័ន្ធទៅនឹងសំណុំលិខិតស្នើសុំ ក្នុងករណីមានពាក្យសុំពន្យារការធ្វើការចុះផ្សាយគំនូរឧស្សាហកម្ម ដូចមានចែងនៅក្នុងមាត្រា ៩៨ នៃច្បាប់នេះ ។ ក្នុងករណីខាងលើនេះ មន្ត្រីកាន់កាប់បញ្ជីត្រូវចុះផ្សាយការបញ្ជាក់អំពីការសុំពន្យារការធ្វើការចុះផ្សាយគំនូរឧស្សាហកម្ម និងពត៌មានដែលបញ្ជាក់អំពីអត្តសញ្ញាណរបស់ម្ចាស់គំនូរឧស្សាហកម្ម ព្រមទាំងបញ្ជាក់អំពីកាលបរិច្ឆេទសុំចុះបញ្ជីសំណុំលិខិតស្នើសុំរយៈពេលនៃការសុំពន្យារ និងចំណុចសំខាន់ៗផ្សេងទៀតដែលបានកំណត់ ។

នៅពេលផុតកំណត់ការពន្យារការធ្វើការចុះផ្សាយ មន្ត្រីកាន់កាប់បញ្ជីត្រូវតែចុះផ្សាយគំនូរឧស្សាហកម្មដែលបានចុះបញ្ជីរួចហើយនោះ ។

នៅក្នុងអំឡុងពេលពន្យារការធ្វើការចុះផ្សាយ ការប្ដឹងអំពីការរំលោភលើគំនូរឧស្សាហកម្មដែលបានចុះបញ្ជីរួចហើយអាចធ្វើទៅបាន លុះត្រាតែអាចកំណត់បានថា បុគ្គលដែលត្រូវបានចោទថារំលោភនោះបានដឹងអំពីពត៌មានដែលមាននៅក្នុងបញ្ជី និងនៅក្នុងឯកសារពាក់ព័ន្ធនឹងសំណុំលិខិតស្នើសុំចុះបញ្ជីគំនូរឧស្សាហកម្មនោះ ។

## ផ្នែកទី ៧

## សិទ្ធិដែលទទួលបានពីការចុះបញ្ជី រយៈពេលការពារ និងការចុះបញ្ជីសារឡើងវិញ

**មាត្រា ១០៥.-**

ការធ្វើអាជីវកម្មដោយបុគ្គលដទៃទៀត ដែលមិនមែនជាម្ចាស់លើគំនូរឧស្សាហកម្មដែលបានចុះបញ្ជីរួចហើយនៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវតែមានការយល់ព្រមពីម្ចាស់ដើម ។

**មាត្រា ១០៦.-**

ក្នុងន័យនៃច្បាប់នេះ ការធ្វើអាជីវកម្មលើគំនូរឧស្សាហកម្មដែលបានចុះបញ្ជីរួចហើយ គឺការផលិត ការលក់ ឬការនាំចូលវត្ថុទាំងឡាយ ដែលបង្កើតឡើងដោយគំនូរឧស្សាហកម្មនោះ ។

**មាត្រា ១០៧.-**

សិទ្ធិទទួលបានពីការចុះបញ្ជីគំនូរឧស្សាហកម្ម មិនអនុវត្តទៅលើសម្ភារៈដែលបានដាក់តាំងនៅលើទីផ្សារនៃព្រះរាជាណាចក្រកម្ពុជា ឬនៅលើទីផ្សារក្រៅព្រះរាជាណាចក្រកម្ពុជាដោយម្ចាស់ ឬដោយមានការយល់ព្រមពីម្ចាស់គំនូរឧស្សាហកម្មនោះទេ ។

**មាត្រា ១០៨.-**

ម្ចាស់គំនូរឧស្សាហកម្មអាចមានសិទ្ធិប្តឹងទៅតុលាការមានសមត្ថកិច្ច ចំពោះបុគ្គលណាដែលរំលោភលើគំនូរឧស្សាហកម្មរបស់ខ្លួនបាន តាមរយៈការអនុវត្តន៍សកម្មភាពទាំងឡាយ ដូចមានចែងនៅក្នុងមាត្រា ១០៦ នៃច្បាប់នេះ ដោយគ្មានការយល់ព្រមពីម្ចាស់ ឬតាមរយៈការអនុវត្តន៍សកម្មភាពដែលបណ្តាលឱ្យមានការរំលោភកើតឡើង ។

**មាត្រា ១០៩.-**

ការចុះបញ្ជីគំនូរឧស្សាហកម្មមានសុពលភាពប្រាំ(៥)ឆ្នាំ ចាប់ពីកាលបរិច្ឆេទសុំចុះបញ្ជីសំណុំលិខិតស្នើសុំ ។ ការចុះបញ្ជីអាចធ្វើសាឡើងវិញបានចំនួនពីរ(២)ដងជាប់ៗគ្នាដែលម្តងៗមានសុពលភាពប្រាំ(៥)ឆ្នាំ ដោយម្ចាស់គំនូរឧស្សាហកម្មត្រូវបង់កម្រៃបន្តសុពលភាពតាមការកំណត់ដូចមានចែងក្នុងមាត្រា ១៣០ នៃច្បាប់នេះ ។ ការយឺតយ៉ាវក្នុងការបង់កម្រៃបន្តសុពលភាពនេះ ត្រូវអនុញ្ញាតយ៉ាងយូរត្រឹមប្រាំមួយ(៦)ខែ ដោយត្រូវមានការបង់កម្រៃបន្ថែមលើការយឺតយ៉ាវនោះ ទៅតាមការកំណត់ដូចមានចែងក្នុងមាត្រា ១៣០ នៃច្បាប់នេះ ។

## ផ្នែកទី ៨

### មោឃភាព

**មាត្រា ១១០.-**

បុគ្គលដែលមានការពាក់ព័ន្ធអាចស្នើសុំទៅតុលាការមានសមត្ថកិច្ចឱ្យទុកជាមោឃៈ នូវការចុះបញ្ជីគំនូរឧស្សាហកម្មបាន ។

**មាត្រា ១១១.-**

តុលាការមានសមត្ថកិច្ចត្រូវចាត់ទុកជាមោឃៈ នូវការចុះបញ្ជីគំនូរឧស្សាហកម្ម ប្រសិនបើបុគ្គលដែលស្នើសុំនោះ បង្ហាញភស្តុតាងថាល័ក្ខខ័ណ្ឌតម្រូវណាមួយនៃផ្នែកទី ១ និងផ្នែកទី ២ នៃជំពូកនេះ មិនបានបំពេញត្រឹមត្រូវ ឬប្រសិនបើអ្នកសុំចុះបញ្ជីមិនមែនជាអ្នកបង្កើតស្នាដៃ ឬមិនមែនជាអ្នកស្នងរបស់អ្នកបង្កើតស្នាដៃ ។

**មាត្រា ១១២.-**

ចំពោះគំនូរឧស្សាហកម្មដែលតុលាការមានសមត្ថកិច្ចសម្រេចចាត់ទុកជាមោឃៈ ការអស់សុពលភាពនោះត្រូវគិតចាប់ពីថ្ងៃចុះបញ្ជីគំនូរឧស្សាហកម្មមក ។

**មាត្រា ១១៣.-**

សេចក្តីសម្រេចជាស្ថាពររបស់តុលាការមានសមត្ថកិច្ចត្រូវជូនដំណឹងដល់មន្ត្រីកាន់កាប់បញ្ជី ដើម្បីឱ្យមន្ត្រីកាន់កាប់បញ្ជីកត់ត្រានិងចុះផ្សាយសេចក្តីសម្រេចរបស់តុលាការឱ្យបានឆាប់រហ័សតាមលទ្ធភាពដែលអាចធ្វើទៅបាន ។

# ជំពូកទី ៦

## បទប្បញ្ញត្តិរួម

### ផ្នែកទី ១

### ការប្ដូរម្ចាស់កម្មសិទ្ធិ និងកិច្ចសន្យាអាជ្ញាប័ណ្ណ

**មាត្រា ១១៤.-**

យោងតាមសំណើរបស់ភាគីដែលពាក់ព័ន្ធមកមន្ត្រីកាន់កាប់បញ្ជី ការប្ដូរម្ចាស់កម្មសិទ្ធិនៃប្រកាសនីយបត្រតក្កកម្ម ឬវិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ ឬការចុះបញ្ជីគំនូរឧស្សាហកម្ម ឬការប្ដូរម្ចាស់កម្មសិទ្ធិនៃសំណុំលិខិតស្នើសុំខាងលើ ត្រូវធ្វើជាលាយលក្ខណ៍អក្សរ ហើយត្រូវកត់ត្រាចូលបញ្ជី និងចុះផ្សាយជាសាធារណៈដោយមន្ត្រីកាន់កាប់បញ្ជី លើកលែងតែករណីនៃសំណុំលិខិតស្នើសុំដែលមិនត្រូវធ្វើការចុះផ្សាយ ។ ការប្ដូរម្ចាស់កម្មសិទ្ធិនេះនឹងមិនមានអានុភាពចំពោះភាគីទីបីឡើយ រហូតដល់ការកត់ត្រាចូលបញ្ជីត្រូវបានធ្វើរួចជាស្ថាពរ ។

**មាត្រា ១១៥.-**

កិច្ចសន្យាអាជ្ញាប័ណ្ណនៃប្រកាសនីយបត្រតក្កកម្ម ឬ វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ ឬគំនូរឧស្សាហកម្មដែលបានចុះបញ្ជីរួចហើយ ឬសំណុំលិខិតស្នើសុំនៃករណីខាងលើនេះ ត្រូវដាក់ជូនទៅមន្ត្រីកាន់កាប់បញ្ជី ។ មន្ត្រីកាន់កាប់បញ្ជីត្រូវរក្សាការសម្ងាត់ដែលមាននៅក្នុងកិច្ចសន្យាអាជ្ញាប័ណ្ណ ប៉ុន្តែត្រូវកត់ត្រាចូលបញ្ជីនិងត្រូវចុះផ្សាយជាសាធារណៈនូវចំណុចគោលមួយចំនួន ។ កិច្ចសន្យាអាជ្ញា

ប័ណ្ណនេះមិនមានអានុភាពចំពោះភាគីទីបីឡើយ រហូតដល់ការកត់ត្រាចូលបញ្ជីត្រូវធ្វើរួចជាស្ថាពរ ។

## ផ្នែកទី ២
## ភ្នាក់ងារ

**មាត្រា ១១៦.-**

ក្នុងករណីអ្នកដាក់ពាក្យសុំមានទីលំនៅអចិន្ត្រៃយ៍ ឬទីតាំងប្រកបអាជីវកម្មសំខាន់ស្ថិតនៅក្រៅព្រះរាជាណាចក្រកម្ពុជា អ្នកស្នើសុំនោះត្រូវតែមានតំណាងជាភ្នាក់ងារដែលមានទីលំនៅ និងកំពុងប្រកបវិជ្ជាជីវៈនៅក្នុងព្រះរាជាណាចក្រកម្ពុជា និងដែលបានបំពេញតាមល័ក្ខខ័ណ្ឌតម្រូវទាំងឡាយដែលបានកំណត់ ។

## ផ្នែកទី ៣
## ការរៀបចំនាយកដ្ឋានទទួលបន្ទុកចុះបញ្ជី

**មាត្រា ១១៧.-**

ក្រសួងទទួលបន្ទុកឧស្សាហកម្ម ត្រូវបង្កើតនាយកដ្ឋានទទួលបន្ទុកចុះបញ្ជីដែលមានតួនាទីទាក់ទងទៅនឹងនីតិវិធីសម្រាប់ :

១-ការផ្តល់ប្រកាសនីយបត្រតក្កកម្ម ការផ្តល់វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងការចុះបញ្ជីគំនូរឧស្សាហកម្ម

២-ការគ្រប់គ្រងប្រកាសនីយបត្រតក្កកម្ម និងវិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ដែលបានផ្តល់ និងគំនូរឧស្សាហកម្មដែលបានចុះបញ្ជីដូចមានចែងនៅក្នុងច្បាប់នេះ និងនៅក្នុងបទបញ្ញា

ទាំងឡាយ ។

## ផ្នែកទី ៤
## បញ្ជី និង ព្រឹត្តិបត្រផ្លូវការ

**មាត្រា ១១៨.-**

ក្រសួងទទួលបន្ទុកឧស្សាហកម្ម ត្រូវមានបញ្ជីពីរដាច់ដោយឡែកពីគ្នា គឺមួយសម្រាប់ប្រកាសនីយបត្រតក្កកម្ម និងវិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងមួយទៀតសម្រាប់គំនូរឧស្សាហកម្ម ។ រាល់ការកត់ត្រាដែលមានចែងនៅក្នុងច្បាប់នេះត្រូវធ្វើនៅក្នុងបញ្ជីខាងលើ ។

បុគ្គលណាក៏ដោយក៏អាចពិនិត្យមើលបញ្ជីខាងលើបាន ហើយអាចដកស្រង់ពត៌មានផ្សេងៗបានស្របទៅតាមល័ក្ខខ័ណ្ឌដែលបានកំណត់ក្នុងបទបញ្ញាទាំងឡាយ ។

**មាត្រា ១១៩.-**

ក្រសួងទទួលបន្ទុកឧស្សាហកម្ម ត្រូវចុះផ្សាយនៅក្នុងព្រឹត្តិបត្រផ្លូវការនូវរាល់ពត៌មានដែលត្រូវចុះផ្សាយជាសាធារណៈដូចមានចែងនៅក្នុងច្បាប់នេះ ។

## ផ្នែកទី ៥

## ការកែកំហុស និងការពន្យារពេល

**មាត្រា ១២០.-**

មន្ត្រីកាន់កាប់បញ្ជីអាចកែតម្រូវរាល់កំហុសក្នុងការបកប្រែ ការកត់ត្រាកំហុសដែលមាននៅក្នុងសំណុំលិខិតស្នើសុំ ឯកសារដែលបានដាក់នៅនាយកដ្ឋានទទួលបន្ទុកចុះបញ្ជី ឬនៅក្នុងការកត់ត្រាផ្សេងៗ បានដោយអនុលោមតាមច្បាប់នេះនិងបទបញ្ញាទាំងឡាយ ។

**មាត្រា ១២១.-**

នៅពេលបានទទួលសំណើសុំជាលាយលក្ខណ៍អក្សរ ប្រសិនបើមន្ត្រីកាន់កាប់បញ្ជីពិនិត្យឃើញថាជាការសមស្រប មន្ត្រីកាន់កាប់បញ្ជីអាចពន្យារពេលបានសម្រាប់អនុវត្តសកម្មភាពណាមួយ ឬប្រកាន់យកចំណាត់ការណាមួយក្រោមច្បាប់នេះ និងក្រោមបទបញ្ញាទាំងឡាយ ដោយជូនដំណឹងដល់ភាគីពាក់ព័ន្ធ និងតាមល័ក្ខខ័ណ្ឌដែលមន្ត្រីកាន់កាប់បញ្ជីណែនាំ ។ ការពន្យារនេះ អាចត្រូវយល់ព្រមបានទោះបីរយៈពេលអនុវត្តនូវសកម្មភាព ឬប្រកាន់យកនូវចំណាត់ការត្រូវផុតកំណត់ហើយក៏ដោយ ។

## ផ្នែកទី ៦

## ការអនុវត្តន៍អំណាចឆន្ទានុសិទ្ធិ

**មាត្រា ១២២.-**

មន្ត្រីកាន់កាប់បញ្ជីត្រូវផ្តល់ឱកាសសម្រាប់សវនាការដល់ភាគីណាមួយនៃបណ្តឹងនៅចំពោះមុខខ្លួន មុនពេលអនុវត្តអំណាច

ឆន្ទានុសិទ្ធិដែលបានប្រគល់ឱ្យដោយច្បាប់នេះ និងដោយបទបញ្ញាទាំងឡាយចំពោះភាគីនោះ ។

## ជំពូកទី ៧
## សមត្ថកិច្ចរបស់តុលាការ និងការប្តឹងតវ៉ា

**មាត្រា ១២៣.-**

វាល់វិវាទដែលបានកើតឡើងពាក់ព័ន្ធទៅនឹងការអនុវត្តន៍ច្បាប់នេះនិងបទបញ្ញាទាំងឡាយ ត្រូវប្តឹងទៅតុលាការមានសមត្ថកិច្ច ។

**មាត្រា ១២៤.-**

សេចក្តីសម្រេចរបស់ក្រសួងទទួលបន្ទុកឧស្សាហកម្ម នៅក្រោមច្បាប់នេះជាពិសេសការផ្តល់ប្រកាសនីយបត្រតក្កកម្ម ការផ្តល់វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ ការចុះបញ្ជីគំនូរឧស្សាហកម្ម ការបដិសេធសំណុំលិខិតស្នើសុំផ្តល់ប្រកាសនីយបត្រតក្កកម្ម ការបដិសេធសំណុំលិខិតស្នើសុំផ្តល់វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ ឬការបដិសេធសំណុំលិខិតស្នើសុំចុះបញ្ជីគំនូរឧស្សាហកម្មអាចជាកម្មវត្ថុនៃការប្តឹងតវ៉ាដោយភាគីពាក់ព័ន្ធទៅតុលាការមានសមត្ថកិច្ចបាន ។បណ្តឹងតវ៉ានោះត្រូវតែដាក់ក្នុងរយៈពេលបី(៣)ខែចាប់ពីថ្ងៃចេញសេចក្តីសម្រេច ។

# ផ្នែកទី ៨
## ការរំលោភ និងសកម្មភាពមិនស្របច្បាប់

**មាត្រា ១២៥.-**

ការរំលោភ គឺជាការអនុវត្តនីសកម្មភាពរំលោភសិទ្ធិទាំងឡាយនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដូចមានចែងក្នុងផ្នែកទី ៩ នៃជំពូកទី ២ និងផ្នែកទី ៧ នៃជំពូកទី ៥ នៃច្បាប់នេះ ដោយបុគ្គលដទៃ និងដោយគ្មានការព្រមព្រៀងពីម្ចាស់ដែលបានទទួលសិទ្ធិការពារ ។

**មាត្រា ១២៦.-**

តាមបណ្ដឹងរបស់ម្ចាស់ដែលបានទទួលសិទ្ធិការពារ ឬរបស់អ្នកទទួលអាជ្ញាប័ណ្ណ ក្រោយពីបានស្នើសុំទៅម្ចាស់ឱ្យប្ដឹងទៅតុលាការមានសមត្ថកិច្ចដើម្បីដោះស្រាយបញ្ហាជាក់លាក់អ្វីមួយ ប៉ុន្តែម្ចាស់នោះបានបដិសេធ ឬខកខានមិនបានធ្វើតាមសំណើនោះទេ តុលាការមានសមត្ថកិច្ចអាចចេញសេចក្ដីសម្រេចបណ្ដោះអាសន្នដើម្បីទប់ស្កាត់ការរំលោភ ឬការរំលោភដែលប្រុងនឹងកើតមានឡើង សម្រេចឱ្យសងការខូចខាត និងផ្ដល់នូវដំណោះស្រាយផ្សេងៗដែលមានចែងក្នុងច្បាប់ផ្សេងទៀតជាធរមាន ។

**មាត្រា ១២៧.-**

ក្នុងករណីកម្មវត្ថុប្រកាសនីយបត្រតក្កកម្ម ឬវិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ជាដំណើរការផលិតកម្មហើយត្រូវចោទប្រកាន់ថាបានប្រព្រឹត្តរំលោភដោយបង្កើតជាផលិតផលតាមរយៈការ

ប្រើប្រាស់ដំណើរការផលិតកម្មរបស់អ្នកចោទប្រកាន់នោះ គឺមិនត្រូវចោទប្រកាន់ទេ ប្រសិនបើផលិតផលនោះ គឺជាផលិតផលថ្មីហើយអ្នកដែលត្រូវចោទប្រកាន់ថារំលោភនោះ បានលើកភស្តុតាងមកបញ្ជាក់ថាផលិតផលនោះមិនត្រូវបានផលិតតាមដំណើរការផលិតកម្មដែលបានចោទប្រកាន់ថារំលោភនោះទេ ។

**មាត្រា ១២៨.-**

ក្នុងការទាមទាររកភស្តុតាងមុនដំណាក់ការជម្រះក្តី ដោយអនុលោមតាមមាត្រា ១២៧ នៃច្បាប់នេះ តុលាការមានសមត្ថកិច្ចត្រូវតែគិតគូរដល់ផលប្រយោជន៍ស្របច្បាប់របស់បុគ្គលដែលត្រូវចោទប្រកាន់ថារំលោភ ដោយមិនធ្វើឱ្យលេចឮខ្ចរខ្ចាយអំពីការសម្ងាត់នៃការផលិត និងការសម្ងាត់នៃរបរជំនួញរបស់បុគ្គលដែលត្រូវចោទប្រកាន់នោះឡើយ ។

## ផ្នែកទី ៩
## ការអនុវត្តន៍សន្ធិសញ្ញាអន្តរជាតិ

**មាត្រា ១២៩.-**

បទប្បញ្ញត្តិទាំងឡាយនៃសន្ធិសញ្ញាអន្តរជាតិ អំពីកម្មសិទ្ធិឧស្សាហកម្មដែលព្រះរាជាណាចក្រកម្ពុជាជាភាគីមួយនៃសន្ធិសញ្ញានោះត្រូវយកមកអនុវត្ត ចំពោះបញ្ហាដែលទាក់ទងជាមួយនឹងច្បាប់នេះបានផងដែរ ។ ក្នុងករណីមានទំនាស់ជាមួយបទប្បញ្ញត្តិទាំងឡាយនៃច្បាប់នេះ បទប្បញ្ញត្តិនៃសន្ធិសញ្ញាអន្តរជាតិនោះត្រូវចាត់ទុកជាបទប្បញ្ញត្តិគោល ។

## ផ្នែកទី ១០

## បទបញ្ជា និងសេចក្ដីណែនាំរដ្ឋបាល

**មាត្រា ១៣០.-**

រដ្ឋមន្ត្រីត្រូវចេញបទបញ្ជាចាំបាច់ណែនាំលំអិត អំពីការអនុវត្តន៍ច្បាប់នេះ ។

ចំពោះការបង់កម្រៃដែលទាក់ទងទៅនឹងការដាក់សំណុំលិខិតស្នើសុំផ្ដល់ប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងសុំចុះបញ្ជីគំនូរឧស្សាហកម្មត្រូវកំណត់ដោយសេចក្ដីប្រកាសរួមរបស់ក្រសួងទទួលបន្ទុកឧស្សាហកម្ម និងក្រសួងទទួលបន្ទុកហិរញ្ញវត្ថុ ។

## ផ្នែកទី ១១

## ការបកស្រាយ

**មាត្រា ១៣១.-**

នៅក្នុងច្បាប់នេះ :

**-ចំណាត់ថ្នាក់អន្តរជាតិ** មានន័យថាចំណាត់ថ្នាក់ដែលអនុលោមតាមកិច្ចព្រមព្រៀងទីក្រុងឡូការណូ ដែលបង្កើតឡើងនូវចំណាត់ថ្នាក់អន្តរជាតិនៃគំនូរឧស្សាហកម្មដែលបានកែសម្រួលចុងក្រោយ ។

- **រដ្ឋមន្ត្រី** មានន័យថារដ្ឋមន្ត្រីទទួលបន្ទុកឧស្សាហកម្ម ។

- **អនុសញ្ញាទីក្រុងប៉ារីស** មានន័យថាអនុសញ្ញាដែលបានចុះហត្ថលេខានៅទីក្រុងប៉ារីស ស្ដីពីការការពារកម្មសិទ្ធិឧស្សាហកម្ម

ចុះថ្ងៃទី ២០ ខែ មីនា ឆ្នាំ ១៨៨៣ ដែលបានកែសម្រួលចុងក្រោយ ។

- **កាលបរិច្ឆេទអាទិភាព** មានន័យថាជាកាលបរិច្ឆេទដែលបានដាក់សំណុំលិខិតស្នើសុំមុនគេបង្អស់ដែលប្រើប្រាស់ធ្វើជាមូលដ្ឋានដើម្បីទទួលសិទ្ធិអាទិភាពដូចបានចែងនៅក្នុងអនុសញ្ញាទីក្រុងប៉ារីស ។

- **មន្ត្រីកាន់កាប់បញ្ជី** មានន័យថាប្រធាននាយកដ្ឋានទទួលបន្ទុកចុះបញ្ជី ។

- **នាយកដ្ឋានទទួលបន្ទុកចុះបញ្ជី** មានន័យថានាយកដ្ឋានកម្មសិទ្ធិឧស្សាហកម្មដែលត្រូវបង្កើតឡើងនៅក្រសួងទទួលបន្ទុកឧស្សាហកម្ម ។

## ជំពូកទី ៧

## ទោសប្បញ្ញត្តិ

**មាត្រា ១៣២.-**

បុគ្គលណាមួយដែលផ្តល់ពត៌មានមិនពិតនៅក្នុងឯកសារដែលបានដាក់ជូនមន្ត្រីកាន់កាប់បញ្ជី ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពីមួយលាន(១.០០០.០០០)រៀល ដល់ប្រាំលាន (៥.០០០.០០០)រៀល ឬត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពីមួយ(១)ខែ ទៅប្រាំមួយ(៦)ខែ ឬត្រូវផ្តន្ទាទោសទាំងពីរខាងលើ ។ ក្នុងករណីមិនរាងចាលក្នុងរយៈពេលប្រាំ(៥)ឆ្នាំ គិតចាប់ពីពេលផ្តន្ទាទោសលើកមុន ត្រូវផ្តន្ទាទោសទ្វេដង ។

**មាត្រា ១៣៣.-**

បុគ្គលណាមួយដែលរំលោភដោយចេតនា ដូចមានចែងក្នុង

មាត្រា ១២៥ ត្រូវផ្តន្ទាទោស ពិន័យជាប្រាក់ពីប្រាំលាន (៥.០០០.០០០)រៀល ដល់ម្ភៃលាន (២០.០០០.០០០)រៀល ឬត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ ពីមួយ(១)ឆ្នាំ ទៅប្រាំ(៥)ឆ្នាំ ឬត្រូវផ្តន្ទាទោសទាំងពីរខាងលើ ។ ក្នុងករណីមិនរាងចាល ក្នុងរយៈពេលប្រាំ(៥)ឆ្នាំ គិតចាប់ពីពេលផ្តន្ទាទោសលើកមុន ត្រូវផ្តន្ទាទោសទ្វេដង។

**មាត្រា ១៣៤.-**

ក្នុងករណីបុគ្គលណាមួយត្រូវបានផ្តន្ទាទោស តុលាការមានសមត្ថកិច្ចអាចបញ្ជាឱ្យធ្វើការរឹបអូសទុកជាសម្បត្តិរដ្ឋ ឬបំផ្លាញចោលនូវទំនិញដែលរំលោភ និងសម្ភារៈឧបករណ៍ដែលយកមកប្រើប្រាស់ក្នុងការប្រព្រឹត្តិរំលោភ ។

**មាត្រា ១៣៥.-**

មន្ត្រីមានសមត្ថកិច្ចណាដែលបានខុសឆ្គងក្នុងការអនុវត្តន៍ភារកិច្ចរបស់ខ្លួនដែលបានផ្តល់ឱ្យស្របតាមច្បាប់នេះ ត្រូវទទួលទោសរដ្ឋបាលដោយពុំទាន់គិតដល់បទល្មើសព្រហ្មទណ្ឌផ្សេងទៀត ។

## ជំពូកទី ៨

## អន្តរប្បញ្ញត្តិ

**មាត្រា ១៣៦.-**

ផលិតផលឱសថ ដូចមានចែងក្នុងមាត្រា ៤ នៃច្បាប់នេះ មិនត្រូវការពារដោយប្រកាសនីយបត្រតក្កកម្ម រហូតដល់ថ្ងៃទី ០១ ខែមករា ឆ្នាំ២ ០១៦ យោងតាមសេចក្តីប្រកាសពត៌មានស្តីពីកិច្ចព្រមព្រៀង

ពាណិជ្ជកម្មពាក់ព័ន្ធកម្មសិទ្ធិបញ្ញា និងសុខភាពសាធារណៈនៃសន្និសីទថ្នាក់រដ្ឋមន្ត្រីរបស់អង្គការពាណិជ្ជកម្មពិភពលោក ចុះថ្ងៃទី ១៤ ខែវិច្ឆិកា ឆ្នាំ ២០០១ នៅទីក្រុងដូហានៃប្រទេសកាតា ។

## ជំពូកទី ៩
## អវសានប្បញ្ញត្តិ

**មាត្រា ១៣៧.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០០៣

**ព្រះហស្តលេខា និង ព្រះរាជលញ្ឆករ**
**នរោត្តម សីហនុ**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ
សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ
**នាយករដ្ឋមន្ត្រី**
**ហត្ថលេខា**
**ហ៊ុន សែន**

បានជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី
**រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល**
**ហត្ថលេខា**
**ស៊ុយ សែម**